រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

# ប្លង់មេរៀន

# សកម្មភាពឃុំ សង្កាត់នៅក្នុងវិស័យអប់រំ

354.968
EDU.COM

sh: training

NCDD Library
000351

ខែកក្កដា ឆ្នាំ២០០៦

# មាតិកាអត្ថបទ


| | |
|---|---|
| កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល | ១ |
| កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល | ៤ |
| ប្លង់មេរៀនទី១ : ប្រព័ន្ធអប់រំនៅកម្ពុជា និងការអប់រំជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ | ៥ |
| ប្លង់មេរៀនទី២ : ការគាំពារ និងការអភិវឌ្ឍកុមារតូច | ១៣ |
| ប្លង់មេរៀនទី៣ : ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ | ២០ |
| ប្លង់មេរៀនទី៤ : ការអប់រំអក្ខរកម្ម | ២៥ |
| ប្លង់មេរៀនទី៥ : បំណិនជីវិត | ៣៦ |
| ប្លង់មេរៀនទី៦ : សមភាពយេនឌ័រក្នុងការអប់រំ | ៣៩ |
| ប្លង់មេរៀនទី៧ : គុណភាពនៃការអប់រំ | ៤៣ |
| ប្លង់មេរៀនទី៨ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន | ៤៨ |

# កិច្ចចាប់ផ្ដើមនៃវគ្គបណ្ដុះបណ្ដាល

មុននឹងចូលដល់មេរៀនទីមួយ អ្នកសម្របសម្រួលអនុវត្តសកម្មភាពមួយចំនួនខាងក្រោម ÷

- ការណែនាំឱ្យស្គាល់គ្នា
- គោលបំណងនៃវគ្គបណ្ដុះបណ្ដាល
- វិន័យសម្រាប់វគ្គបណ្ដុះបណ្ដាល
- សិក្ខាកាមដែលចូលរួមវគ្គបណ្ដុះបណ្ដាលនៅថ្នាក់ឃុំ សង្កាត់
- កម្មវិធីបណ្ដុះបណ្ដាល
- ការណែនាំអំពីរបៀបបំពេញទម្រង់វាយតម្លៃវគ្គបណ្ដុះបណ្ដាល

## ១). ការណែនាំឱ្យស្គាល់គ្នា (ប្រហែល១០នាទី)

អ្នកសម្របសម្រួលអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ក្នុងការណែនាំឱ្យស្គាល់គ្នា ដើម្បីឱ្យស្គាល់ឈ្មោះ តួនាទី ទីកន្លែងធ្វើការងារ ឬកន្លែងរស់នៅ ចំណង់ចំណូលចិត្ត . . . ។ល។

## ២). គោលបំណងនៃវគ្គបណ្ដុះបណ្ដាល (ប្រហែល៣នាទី)

អ្នកសម្របសម្រួលជម្រាបគោលបំណងនៃវគ្គបណ្ដុះបណ្ដាលដល់សិក្ខាកាម។ នៅចុងបញ្ចប់នៃវគ្គបណ្ដុះបណ្ដាលនេះ សិក្ខាកាមនឹង ÷

១. យល់ដឹងអំពីសារៈសំខាន់នៃការអប់រំ

២. កំណត់បាននូវបញ្ហាដែលពាក់ព័ន្ធនឹងការអប់រំមួយចំនួនដែលប៉ះពាល់លើនារី និងកុមារ និងរកឃើញនូវមូលហេតុនៃបញ្ហាដែលកើតមានឡើងទាំងនោះ។

៣. កំណត់បាននូវសេវាអប់រំសមស្រប ដើម្បីដោះស្រាយបញ្ហាដែលកើតឡើង។

៤. រៀបចំបាននូវផែនការសកម្មភាពដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្ត ដើម្បីដោះស្រាយបញ្ហាដែលពាក់ពន្ធ័ នឹងការអប់រំ។

## ៣). វិន័យសម្រាប់វគ្គបណ្ដុះបណ្ដាល (ប្រហែល៥នាទី)

អ្នកសម្របសម្រួលរួមជាមួយសិក្ខាកាម កំណត់វិន័យសម្រាប់វគ្គបណ្ដុះបណ្ដាល។

## ៤). សិក្ខាកាមនៅថ្នាក់ឃុំ សង្កាត់ (ប្រហែល៥នាទី)

ការបណ្ដុះបណ្ដាលនៅថ្នាក់ឃុំ សង្កាត់ ក្នុងមួយវគ្គៗ មានសិក្ខាកាមចូលរួមពី២៥ ទៅ៣០នាក់។ ឃុំ សង្កាត់នីមួយៗ មានចំនួនសិក្ខាកាម៨នាក់ ក្នុងនោះរួមមាន ÷

- មេឃុំ ចៅសង្កាត់
- ជំទប់ទី២ ចៅសង្កាត់រងទី២
- អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
- មេភូមិ១នាក់

- គ្រូថ្នាក់អក្ខរកម្ម ឬគ្រូស្ម័គ្រចិត្ត ឬគ្រូមត្តេយ្យ
- នាយកសាលាបឋមសិក្សា ឬមធ្យមសិក្សាបឋមភូមិ
- តំណាងមាតាបិតាសិស្ស

## ៥). កម្មវិធីបណ្ដុះបណ្ដាល (ប្រហែល៥នាទី)

អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមអំពីកម្មវិធីបណ្ដុះបណ្ដាល ។

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| | ថ្ងៃទី១ | |
| 07:30-08:00 | ការមកដល់របស់សិក្ខាកាម និងភ្ញៀវ | |
| 08:00-08:30 | កិច្ចចាប់ផ្ដើមនៃវគ្គបណ្ដុះបណ្ដាល | |
| 08:30-10:00 | មេរៀនទី១ : ប្រព័ន្ធអប់រំនៅកម្ពុជា និងការអប់រំជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ | |
| 10:00-10:15 | សម្រាកអាហារសម្រន់ តែ កាហ្វេ | |
| 10:15-11:30 | មេរៀនទី២ : ការគាំពារ និងការអភិវឌ្ឍកុមារតូច | |
| 11:30-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:30 | មេរៀនទី៣ : ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ | |
| 15:30-15:45 | សម្រាកអាហារសម្រន់ តែ កាហ្វេ | |
| 15:45-17:30 | មេរៀនទី៤ : ការអប់រំអក្ខរកម្ម | |
| | ថ្ងៃទី២ | |
| 08:00-08:45 | មេរៀនទី៥ : បំណិនជីវិត | |
| 08:45-10:00 | មេរៀនទី៦ : សមភាពយេនឌ័រក្នុងការអប់រំ | |
| 10:00-10:15 | សម្រាកអាហារសម្រន់ តែ កាហ្វេ | |
| 10:15-11:30 | មេរៀនទី៧ : គុណភាពនៃការអប់រំ | |
| 11:30-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-16:30 | មេរៀនទី៨ : ការបូកសរុបផែនការសកម្មភាព | |

## ៦). ការណែនាំអំពីរបៀបបំពេញទម្រង់វាយតម្លៃវគ្គបណ្ដុះបណ្ដាល (ប្រហែល១០នាទី)

អ្នកសម្របសម្រួលត្រូវពន្យល់អំពីរបៀបបំពេញទម្រង់វាយតម្លៃ និងរំលឹកដល់សិក្ខាកាមឱ្យបំពេញទម្រង់វាយតម្លៃបន្ទាប់ពីបញ្ចប់មេរៀននីមួយៗ ។

# ការវាយតម្លៃវគ្គបណ្តុះបណ្តាលស្តីពីសកម្មភាពឃុំ សង្កាត់នៅក្នុងវិស័យអប់រំ

## (Training Evaluation on Commune/Sangkat Actions on Education)

| | ខ្លឹមសារមេរៀន Content | | | | | | | | | | ការសម្របសម្រួល Facilitation | | | | | | | | | | លំហាត់ និងការអនុវត្តជាក់ស្តែង Exercise | | | | | | | | | | ពេលវេលា Time | | | | | | | | | | កម្រិតយល់ដឹងរបស់សិក្ខាកាម Level of Understanding | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មេរៀន | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| Lesson | អន់ (Bad) | | | | | | | | | ល្អ (Good) | អន់ (Bad) | | | | | | | | | ល្អ (Good) | អន់ (Bad) | | | | | | | | | ល្អ (Good) | អន់ (Bad) | | | | | | | | | ល្អ (Good) | អន់ (Bad) | | | | | | | | | ល្អ (Good) |
| 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

មតិយោបល់ផ្សេងៗ (Other Comments)

# កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

១). អ្នកសម្របសម្រួល និងអ្នកជំនួយការបច្ចេកទេស

ឯកសារបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងសម្រាប់អ្នកដែលមានជំនាញសម្របសម្រួល និងធ្លាប់មានបទពិសោធន៍ពាក់ព័ន្ធនឹងបញ្ហានារីនិងកុមារ និងវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា ដើម្បីបណ្តុះបណ្តាលបន្តដល់ថ្នាក់ឃុំ សង្កាត់។

អ្នកជំនួយការបច្ចេកទេស គឺតំណាងមកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ឬ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខណ្ឌ។

២). តួនាទីរបស់អ្នកសម្របសម្រួល និងអ្នកជំនួយការបច្ចេកទេស

អ្នកសម្របសម្រួល និងអ្នកជំនួយការបច្ចេកទេស នឹងបំពេញតួនាទីខុសៗគ្នា ប៉ុន្តែបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីធ្វើឱ្យសិក្ខាកាមរៀនសូត្រប្រកបដោយប្រសិទ្ធភាព ។ ជាប្រការមួយសំខាន់ ដែលអ្នកសម្របសម្រួលធ្វើការពិភាក្សាជាមួយអ្នកជំនួយបច្ចេកទេស មុននឹងដំណើរការវគ្គបណ្តុះបណ្តាល ដើម្បីបែងចែកការងារ និងមេរៀនដែលត្រូវសម្របសម្រួល ។

ប្លង់មេរៀននេះ ត្រូវបានរៀបចំឡើងដោយបានធ្វើការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលជាច្រើនសា ហេតុដូចនេះ អ្នកសម្របសម្រួលត្រូវតែអនុវត្តតាមការណែនាំនៅក្នុងប្លង់មេរៀននេះជាចាំបាច់ ។ ប្រសិនបើអ្នកសម្របសម្រួលគ្រប់គ្រងពេលវេលានៃការបណ្តុះបណ្តាលបានល្អ នោះការបណ្តុះបណ្តាលនឹងដំណើរការបានយ៉ាងរលូន ហើយបញ្ចប់តាមការគ្រោងទុក ។

## ក). អ្នកសម្របសម្រួល

អ្នកសម្របសម្រួល មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- ត្រៀមរៀបចំឯកសារ និងសម្ភារសម្រាប់ការបណ្តុះបណ្តាល
- គោរព និងអនុវត្តតាមសកម្មភាពដែលបានពិពណ៌នា នៅក្នុងប្លង់មេរៀន
- សម្របសម្រួលការពិភាក្សាជាក្រុម

## ខ). អ្នកជំនួយការបច្ចេកទេស

អ្នកជំនួយការបច្ចេកទេស មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- សហការជាមួយអ្នកសម្របសម្រួល ក្នុងការបញ្ជាក់បន្ថែមលើខ្លឹមសារបច្ចេកទេស បើចាំបាច់
- សហការជាមួយអ្នកសម្របសម្រួល ក្នុងការសម្របសម្រួលដំណើរការវគ្គបណ្តុះបណ្តាល
- សម្របសម្រួលមេរៀនមួយចំនួន ឬផ្នែកមួយចំនួននៃមេរៀន ទៅតាមការពិភាក្សា និងឯកភាពជាមួយអ្នកសម្របសម្រួល
- សហការជាមួយអ្នកសម្របសម្រួល ក្នុងការសម្របសម្រួលក្រុមពិភាក្សា
- សង្កេតសកម្មភាពបណ្តុះបណ្តាល និងផ្តល់យោបល់ដល់អ្នកសម្របសម្រួល នៅពេលបញ្ចប់មេរៀននីមួយៗ

# ប្លង់មេរៀនទី១

# ប្រព័ន្ធអប់រំនៅកម្ពុជា និងការអប់រំជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីសារប្រយោជន៍នៃការអប់រំ<br>• លើកកម្ពស់ស្ថានភាពអប់រំឱ្យទៅជាអាទិភាពរបស់ឃុំ សង្កាត់ ។ |
| រយៈពេលសរុប | ប្រហែល ៩០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសអា៤ និងឯកសារលំហាត់ ១.១. ១.២។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ពិភាក្សាជាក្រុម ការបង្ហាញ និងល្បែងយល់ដឹងពីប្រព័ន្ធអប់រំនៅកម្ពុជា។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | **១. ការបំផុសសំណួរ និងការបង្ហាញខ្លឹមសារមេរៀន**<br>អ្នកសម្របសម្រួលត្រូវចាប់ផ្តើមមេរៀននេះដោយសួរទៅសិក្ខាកាមថា : មុនពេលយើងឈានចូលដល់បញ្ហាការអប់រំ តើលោកអ្នកយល់ដូចម្តេចដែរចំពោះពាក្យថា "*ការអប់រំ*" និងពាក្យថា "*ភាពក្រីក្រ*"?។ អ្នកសម្របសម្រួលត្រូវកត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្រដាសផ្ទាំងធំ ។<br>ចម្លើយអាចមាន : | ខ្លឹមសារ មេរៀន១.១ |

| *ការអប់រំ :* | *ភាពក្រីក្រ :* |
|---|---|
| - ការបណ្តុះបណ្តាល ឬការបង្រៀន | - អាហារពុំគ្រប់គ្រាន់ |
| - ការរៀនសូត្រ | - ពុំមានប្រាក់ |
| - ការបញ្ជូនកូនឱ្យទៅរៀន | - ទីលំនៅមិនសមរម្យ |
| - ការផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ | - សម្លៀកបំពាក់ពុំសមរម្យ |
| - ឱ្យប្រជាពលរដ្ឋរៀនសូត្រ | - ប្រាក់ចំណូលតិច |
| - ធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា | - គ្មានការងារធ្វើ |
| - មានគំនិត និងទស្សនទានយល់ដឹងពីសង្គម | - ពុំមានដីស្រែគ្រប់គ្រាន់ |

បន្ទាប់ពីបំផុសសំណួរនេះចប់ អ្នកសម្របសម្រួលបូកសរុបគំនិតទាំងនោះ ដោយបង្ហាញខ្លឹមសារមេរៀនត្រង់ចំណុច ១.១.និយមន័យនៃពាក្យ *ការអប់រំ* និង *ភាពក្រីក្រ* ដែលមានខ្លឹមសារដូចខាងក្រោម :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ការអប់រំ គឺជាដំណើរការនៃការរៀនសូត្រ ឬការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍន៍ផ្នែកកាយ ប្រាជ្ញា ស្មារតី និង សីលធម៌របស់បុគ្គល តាមរយៈកម្មវិធីច្បាស់លាស់ ឬតាមមធ្យោបាយផ្សេងៗទៀត ដែលអ្នករៀនសូត្រទាំងនោះ អាចទទួលបានចំណេះដឹង ជំនាញ សមត្ថភាព និងបំណិនជីវិត សម្រាប់ខ្លួនគេផ្ទាល់ និងសម្រាប់សង្គមជាតិទាំងមូល ។<br><br>ភាពក្រីក្រ គឺជាភាពនៃការខ្វះអាហារ ខ្វះសម្លៀកបំពាក់ ខ្វះទីជម្រករស់នៅ ឬគ្មានទីជម្រកសម្រាប់រស់នៅ ខ្វះសេវាសុខភាព សេវាអប់រំ និងប្រព័ន្ធគមនាគមន៍ ។ | |
| ១២នាទី | ២. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ១.២.ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងការអប់រំនៅប្រទេសកម្ពុជា និង ១.៣.គោលដៅទាំង៦នៃការអប់រំសម្រាប់ទាំងអស់គ្នា ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់ បកស្រាយ ។ | ខ្លឹមសារមេរៀន១.២ និង ១.៣ |
| ៣នាទី | ៣. ការបញ្ជាក់<br>អ្នកសម្របសម្រួលត្រូវបន្តដោយលើកឡើងថា នៅក្នុងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥ ៖ ជាការពិត យើងទទួលស្គាល់ថាផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នានេះ ជាភារកិច្ច និងការទទួលខុសត្រូវរបស់ប្រទេសជាតិនីមួយៗ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សម្រាប់ប្រទេសក្រីក្រដូចប្រទេសកម្ពុជាយើង ពិតជាត្រូវការយ៉ាងចាំបាច់នូវកិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភគាំទ្រពីសហគមន៍ជាតិ និងអន្តរជាតិ ដើម្បីសម្រេចឱ្យបានតាមទិសដៅប្រកបដោយមហិច្ឆតានេះ ។ នេះមានន័យថា ៖ "ការអប់រំ មិនមែនគ្រាន់តែជាការទទួលខុសត្រូវរបស់ក្រសួងអប់រំ យុវជន និងកីឡាប៉ុណ្ណោះទេ តែវាជាកិច្ចការរបស់ប្រជាពលរដ្ឋគ្រប់រូប និងរបស់គ្រប់តួអង្គនៃការអភិវឌ្ឍ" ។ | |
| ១០នាទី | ៤. ការបំផុសសំណួរ និងការបង្ហាញខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលត្រូវបន្តដោយសួរសិក្ខាកាមថា ៖ តើការអប់រំផ្តល់សារប្រយោជន៍អ្វីខ្លះ?។ អ្នកសម្របសម្រួលត្រូវកត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។ | ខ្លឹមសារមេរៀន១.៤ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ចម្លើយដែលអាចមាន :<br>• ចេះអាន និងសរសេរ<br>• យល់ដឹងលើឯកសារព័ត៌មានផ្សេងៗ<br>• ចេះគិតលេខ<br>• ងាយស្រួលក្នុងការទទួលបាននូវព័ត៌មានផ្សេងៗ<br>• អាចទទួលបាននូវចំណេះដឹងបច្ចេកទេសផ្សេងៗ<br>• ក្លាយជាមនុស្សល្អប្រសើរ ។<br>• . . . ។ល ។<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ១.៤.គោលការណ៍៤យ៉ាងនៃការអប់រំ ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ។ | |
| ១០នាទី | **៥. ការបំផុសសំណួរ និងការបង្ហាញខ្លឹមសារមេរៀន**<br>អ្នកសម្របសម្រួលបំផុសសំណួរថា តើប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា មានកម្រិតអ្វីខ្លះ? ។ ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។<br>ចម្លើយអាចមាន :<br>• មត្តេយ្យសិក្សា<br>• បឋមសិក្សា<br>• មធ្យមសិក្សាបឋមភូមិ ឬអនុវិទ្យាល័យ<br>• មធ្យមសិក្សាទុតិយភូមិ ឬវិទ្យាល័យ<br>• ឧត្តមសិក្សា ឬមហាវិទ្យាល័យ<br>បន្ទាប់មកអ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ១.៥.ប្រព័ន្ធអប់រំនៅកម្ពុជា ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ។ | ខ្លឹមសារ មេរៀន១.៥ |
| ១៥នាទី | **៦. ការបំផុសសំណួរ និងការបង្ហាញខ្លឹមសារមេរៀន**<br>អ្នកសម្របសម្រួលសួរទៅសិក្ខាកាមថា តើការអប់រំអាចជួយកាត់បន្ថយភាពក្រីក្រយ៉ាងដូចម្តេចខ្លះ? អ្នកសម្របសម្រួលត្រូវកត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ចម្លើយអាចមាន :<br>• បង្កើនផលិតកម្មកសិកម្ម<br>• អាចឱ្យយើងទទួលបានព័ត៌មានដែលទាក់ទងនឹងការថែទាំសុខភាព<br>• ជួយកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ<br>• កាត់បន្ថយការគេងប្រវ័ញ្ចផ្លូវភេទ<br>• អាចទទួលបានការងារធ្វើ<br>• អាចបើកអាជីវកម្មធុនតូច ដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់គ្រួសារ<br>• អាចគិតពីមធ្យោបាយ ដើម្បីជួយខ្លួនឯង<br>• គិតថាខ្លួនមានប្រយោជន៍ និងជឿជាក់លើខ្លួនឯង<br>• ចេះរស់នៅក្នុងសហគមន៍ដោយមានសាមគ្គីភាព<br>• . . . ។ល ។<br>អ្នកសម្របសម្រួលត្រូវសំយោគយោបល់ ដោយធ្វើសេចក្តីសន្និដ្ឋានជូនសិក្ខាកាមថា សារប្រយោជន៍នៃការអប់រំដែលមាននៅក្នុងចម្លើយ ដែលបានលើកឡើងទាំងនេះ គឺសុទ្ធតែអាចជួយកាត់បន្ថយភាពក្រីក្រ ។<br><br>អ្នកសម្របសម្រួលត្រូវបន្តសំណួរថា : យើងទាំងអស់គ្នាបានដឹងពីផលប្រយោជន៍នៃការអប់រំហើយ **តើយើងទទួលបានការអប់រំពីកន្លែងណាខ្លះ?**។ កត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។<br>ចម្លើយអាចមាន :<br>• **នៅសាលារៀន** : ថ្នាក់ថែទាំកុមារ មត្តេយ្យសាលា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ...។<br>• **នៅផ្ទះ** (គ្រួសារ) : ទទួលការអប់រំពីឪពុកម្តាយ ជីដូនជីតា ពីសាច់ញាតិ និងបងប្អូន ...។<br>• សហគមន៍ (វត្តអារាម សាលាឃុំ សង្កាត់) : ថ្នាក់អក្ខរកម្ម ថ្នាក់ហ្វឹកហ្វឺនពីបំណិនជីវិត ការងារអនុវត្តជាក់ស្តែងនៅក្នុងសហគមន៍ ។<br><br>អ្នកសម្របសម្រួលបញ្ចប់សកម្មភាពនេះ ដោយស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ១.៦.កន្លែងផ្តល់ការអប់រំ និង១.៧.ការអប់រំចូលរួមកាត់បន្ថយភាពក្រីក្រ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុច១។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ។ | |
| ២០នាទី | ៧. លំហាត់ ១.១.<br>អ្នកសម្របសម្រួលត្រូវចែកសិក្ខាកាមជាក្រុមដែលមានសមាជិកពី ៥-៦នាក់ ហើយចែកឱ្យក្រុមនីមួយៗនូវឯកសារលំហាត់ ១.១. ក្រដាសអា៤ និងហ្វឺតសម្រាប់សរសេរចម្លើយ។ អ្នកសម្របសម្រួលត្រូវពន្យល់ថា យើងនឹងមានការប្រកួតប្រជែងឆ្លើយនូវសំណួរដើម្បីឱ្យដឹងថា តើលោកអ្នកយល់ដឹងពីប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជាបានកម្រិតណា?។ ខ្ញុំនឹងអានសំណួរម្តងមួយៗជូនលោកអ្នក បន្ទាប់មកលោកអ្នកត្រូវពិភាក្សាក្នុងក្រុម ហើយនៅពេលរកឃើញចម្លើយ ត្រូវសរសេរចម្លើយនោះដាក់លើក្រដាសអា៤ដែលបានបែងចែកជូន និងបន្ទាប់មកត្រូវលើកបង្ហាញ។ ក្រុមណាដែលឆ្លើយត្រូវ ក្រុមនោះនឹងទទួលបានមួយពិន្ទុសម្រាប់សំណួរនីមួយៗ។ ផ្ទុយមកវិញចំពោះចម្លើយខុសនឹងទទួលបានពិន្ទុសូន្យ។ នៅចុងបញ្ចប់ ក្រុមដែលទទួលបានពិន្ទុច្រើនជាងគេជាក្រុមឈ្នះ។<br><br>បន្ទាប់ពីបញ្ចប់សំណួរ និងចម្លើយ អ្នកសម្របសម្រួលចែកចម្លើយលំហាត់ ១.១ ដល់គ្រប់សិក្ខាកាម ហើយទុកពេលវេលាសមស្របជូនសិក្ខាកាមផ្ទៀងផ្ទាត់ និងមានសំណួរ បើសិនជាមានចម្ងល់ផ្សេងៗ។ | -ក្រដាសអា៤<br>ហ្វឺត<br>-ឯកសារ<br>លំហាត់១.១ |
| ៥នាទី | ៨. ការបញ្ជាក់<br>អ្នកសម្របសម្រួលត្រូវលើកឡើងថា ជាទូទៅ "ភាពក្រីក្រ" ឬ "ភាពគ្មានលុយកាក់" ត្រូវបានគេនិយាយ វាជាមូលហេតុដែលធ្វើឱ្យកុមារមិនបានចូលសាលារៀន ។ អ្នកសម្របសម្រួលត្រូវប្រើឱកាសនេះ ដើម្បីបកស្រាយបញ្ហានេះដោយបង្ហាញថា :<br>"បច្ចុប្បន្នប្រព័ន្ធអប់រំប្រទេសកម្ពុជា គឺ "ជាបរិយាប័ន្ន (ការអប់រំបញ្ចូលគ្នា)" មានន័យថា ទាំងកុមារាទាំងកុមារី មានសិទ្ធិទទួលបានការអប់រំស្មើៗគ្នា ទោះបីក្រីក្រ ពិការ កំព្រា កុមារជនជាតិភាគតិច កុមារនៅតំបន់ដាច់ស្រយាល កុមារអនាថា ...។ល។ លើសពីនេះទៅទៀត ការបង់ថ្លៃគ្រប់រូបភាព ត្រូវបានលុបបំបាត់ចោល ។ ដូចនេះ កុមារមិនគួរគេចសាលារៀនដោយសារតែជីវភាពគ្រួសារក្រខ្សត់ឡើយ"។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **៩. ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលបញ្ជាក់ថា : នៅក្នុងវគ្គនេះ យើងទាំងអស់គ្នានឹងពិនិត្យមើលពីទិដ្ឋភាពជាក់ស្តែងស្តីពីការអប់រំអាចកាត់បន្ថយភាពក្រីក្រ។ ក្នុងនាមលោកអ្នកជាអ្នកដឹកនាំឃុំ សង្កាត់ និងភូមិ យើងទាំងអស់គ្នាមានភារកិច្ចយ៉ាងច្រើន ដើម្បីធ្វើឱ្យការអប់រំនៅក្នុងឃុំ សង្កាត់របស់យើងមានភាពល្អប្រសើរឡើង។ ដូច្នេះនៅក្នុងវគ្គបណ្តុះបណ្តាលនេះ យើងចង់ឱ្យលោកអ្នកគិតអំពីអ្វីដែលអាចធ្វើបាន ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកដឹកនាំសហគមន៍ ដើម្បីជួយកុមារឱ្យមាន លទ្ធភាពទទួលបានការអប់រំ ទទួលបាននូវសក្តានុពលពេញលេញ ដែលនោះគឺវាជាសិទ្ធិរបស់កុមារគ្រប់រូបក្នុងការទៅសាលារៀន។ យើងត្រូវតែជួយគេឱ្យស្គាល់ពីសិទ្ធិមូលដ្ឋាននេះ។<br><br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ១.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែម ទៅក្នុងឯកសារលំហាត់១.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារ<br>លំហាត់១.២ |

## ឯកសារលំហាត់ ១.១

| សំណួរ | ចម្លើយត្រឹមត្រូវ |
|---|---|
| ១. តើមានកន្លែងណាខ្លះសម្រាប់ឱ្យកុមារអាយុពី៣ ទៅក្រោម៦ឆ្នាំទទួលបានការសិក្សាអប់រំ? | |
| ២. តើកុមារអាយុប៉ុន្មានឆ្នាំត្រូវចុះឈ្មោះចូលរៀនថ្នាក់ទី១នៅបឋមសិក្សា? | |
| ៣. តើកុមារត្រូវសិក្សាប៉ុន្មានថ្នាក់ដើម្បីបញ្ចប់ថ្នាក់បឋមសិក្សា? | |
| ៤. តើសិស្សានុសិស្សត្រូវបង់ថ្លៃប៉ុន្មានដើម្បីចូលរៀននៅបឋមសិក្សា? | |
| ៥. តើមានប៉ុន្មានកម្រិតថ្នាក់នៅក្នុងមធ្យមសិក្សាបឋមភូមិ? | |
| ៦. តើមានប៉ុន្មានកម្រិតថ្នាក់ចំពោះការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ?<br>ក. ៦កម្រិតថ្នាក់ ខ. ៩កម្រិតថ្នាក់ គ. ១២កម្រិតថ្នាក់ | |
| ៧. តើការអប់រំមូលដ្ឋានមានថ្នាក់ទីប៉ុន្មានខ្លះ? | |
| ៨. ឧទាហរណ៍ថា មានក្មេងអាយុ១២ឆ្នាំម្នាក់ដែលមិនទាន់ចេះអាន និងសរសេរ តើគេអាចទៅរៀននៅទីណា? | |
| ៩. តើកម្មវិធីដូចជា ថ្នាក់អក្ខរកម្ម ត្រូវគេហៅថាយ៉ាងដូចម្តេច?<br>ក. ការអប់រំក្នុងប្រព័ន្ធ ខ. ការអប់រំក្រៅប្រព័ន្ធ | |

## ចម្លើយលំហាត់ ១.១

| សំណួរ | ចម្លើយត្រឹមត្រូវ |
|---|---|
| ១. តើមានកន្លែងណាខ្លះសម្រាប់ឱ្យកុមារអាយុពី៣ ទៅក្រោម៦ឆ្នាំទទួលបានការអប់រំសិក្សា? | មត្តេយ្យសិក្សារដ្ឋ<br>មត្តេយ្យឯកជន<br>មត្តេយ្យសិក្សាសហគមន៍ |
| ២. តើកុមារអាយុប៉ុន្មានឆ្នាំត្រូវចុះឈ្មោះចូលរៀនថ្នាក់ទី១នៅបឋមសិក្សា? | ៦ឆ្នាំ |
| ៣. តើកុមារត្រូវសិក្សាប៉ុន្មានថ្នាក់ដើម្បីបញ្ចប់ថ្នាក់បឋមសិក្សា? | ៦កម្រិតថ្នាក់ |
| ៤. តើសិស្សានុសិស្សត្រូវបង់ថ្លៃប៉ុន្មានដើម្បីចូលរៀននៅបឋមសិក្សា? | គ្មានការបង់ប្រាក់ទេ |
| ៥. តើមានប៉ុន្មានកម្រិតថ្នាក់នៅក្នុងមធ្យមសិក្សាបឋមភូមិ? | ៣កម្រិតថ្នាក់ |
| ៦. តើមានប៉ុន្មានកម្រិតថ្នាក់ចំពោះការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ?<br>ក. ៦កម្រិតថ្នាក់ ខ. ៩កម្រិតថ្នាក់ គ. ១២កម្រិតថ្នាក់ | ខ.-៩ កម្រិតថ្នាក់<br>(រៀនចប់ថ្នាក់ទី៩) |
| ៧. តើការអប់រំមូលដ្ឋានមានថ្នាក់ទីប៉ុន្មានខ្លះ? | កម្រិតថ្នាក់ទី១-៦, ៧-៩ |
| ៨. ឧទាហរណ៍ថា មានក្មេងអាយុ១២ឆ្នាំម្នាក់ដែលមិនទាន់ចេះអាន និងសរសេរ តើគេអាចទៅរៀននៅទីណា? | ថ្នាក់អក្ខរកម្ម ឬបឋមសិក្សាដែលនៅជិត |
| ៩. តើកម្មវិធីដូចជា ថ្នាក់អក្ខរកម្ម ត្រូវគេហៅថាយ៉ាងដូចម្តេច?<br>ក. ការអប់រំក្នុងប្រព័ន្ធ ខ. ការអប់រំក្រៅប្រព័ន្ធ | ខ.ការអប់រំក្រៅប្រព័ន្ធ |

## ឯកសារលំហាត់ ១.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ផ្សព្វផ្សាយពីសារៈសំខាន់ និងព័ត៌មាននៃការអប់រំដល់ប្រជាពលរដ្ឋ
- ណែនាំគណៈកម្មការពាក់ព័ន្ធផ្នែកអប់រំដល់ប្រជាពលរដ្ឋ
- បញ្ចូលក្នុងរបៀបវារៈអង្គប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ពិចារណាសកម្មភាពអប់រំជាសកម្មភាពអាទិភាពក្នុងផែនការឃុំ សង្កាត់

# ប្លង់មេរៀនទី២

# ការគាំពារ និងការអភិវឌ្ឍកុមារតូច

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីសារៈសំខាន់នៃការគាំពារ និងការអភិវឌ្ឍកុមារតូច និងផលប៉ះពាល់របស់វាទៅលើអនាគតនៃកុមារតូច។<br>• មានលទ្ធភាពរៀបចំសកម្មភាពមួយចំនួនដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តដើម្បីជំរុញឱ្យមានសេវាថែទាំកុមារតូច និងថ្នាក់មត្តេយ្យសម្រាប់កុមារអាយុពី៣-៥ឆ្នាំ នៅក្នុងមូលដ្ឋានរបស់ខ្លួន។ |
| រយៈពេលសរុប | ប្រហែល ១០០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ផ្ទាំងរូបភាពស្តីពីការគាំពារ និងការអភិវឌ្ឍកុមារតូច (កន្លែងដែលមានវីដេអូ សូមប្រើខ្សែវីដេអូឯកសារស្តីពីការគាំពារ និងការអភិវឌ្ឍកុមារតូច) និងឯកសារលំហាត់ ២.១. ២.២។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការពិភាក្សាជាក្រុម ការទស្សនាវីដេអូ និងការបង្ហាញ។ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | ១. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលត្រូវចាប់ផ្តើមមេរៀនដោយសួរសិក្ខាកាមថា :<br>• ក្នុងចំណោមលោកអ្នក តើអ្នកណាខ្លះដែលមានកូន ឬចៅអាយុក្រោម៦ឆ្នាំ?<br>• តើក្មេងទាំងនោះធ្វើអ្វីខ្លះ?<br>អ្នកសម្របសម្រួល កត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន ឬក្រដាសផ្ទាំងធំចំពោះសំណួរចុងក្រោយ។<br>ចម្លើយអាចមាន :<br>• នៅផ្ទះជាមួយម្តាយ ឬជីដូន<br>• នៅផ្ទះជាមួយបង ឬសាច់ញាតិ<br>• ទៅរៀននៅថ្នាក់មត្តេយ្យ<br>• ទៅរៀននៅមណ្ឌលថែទាំកុមារតូច។ | |
| ៥នាទី | ២. ការបំផុសសំណួរ និងបង្ហាញខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលបន្តដោយលើកសំណួរថា តើហេតុអ្វីបានជាចាំបាច់គាំពារកុមារតាំងពីដំបូង?។ កត់ត្រាចម្លើយរបស់សិក្ខាកាម។ បន្ទាប់មកអ្នកសម្របសម្រួល | ខ្លឹមសារមេរៀន២.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | បង្ហាញខ្លឹមសារខាងក្រោម (ខ្លឹមសារមេរៀន ២.១) :<br>"គាំពារពីដំបូងទៅលើកុមារតូច ពិតជាមានសារប្រយោជន៍ខ្លាំងណាស់ចំពោះការជួយគាំពារពីដំបូងទៅលើកុមារតូចៗ ព្រោះវានឹងមានផលប៉ះពាល់វិជ្ជមានលើកុមារ។ ជាពិសេសលើការអភិវឌ្ឍផ្នែកខួរក្បាល ដែលជាទូទៅការអភិវឌ្ឍផ្នែកខួរក្បាលនេះ វាលូតលាស់យ៉ាងឆាប់រហ័ស នៅក្នុងខែនិងឆ្នាំដំបូងរបស់កុមារ។ កង្វះការយកចិត្តទុកដាក់ គឺនាំឱ្យមានផលប៉ះពាល់អវិជ្ជមានឥតឈប់ឈរទៅលើកុមារ ដែលនាំឱ្យមានការខូចខាតលើសពីអ្វីដែលយើងបានគិតទុកពីមុន"។ | |
| ២៥នាទី | ៣. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលត្រូវបង្ហាញផ្ទាំងរូបភាពមួយចំនួន (ឬខ្សែវីដេអូឯកសារ) ដើម្បីផ្តល់ឱកាសឱ្យសិក្ខាកាមបានស្វែងយល់កាន់តែច្បាស់ ពីសារៈសំខាន់នៃការថែទាំ និងការអប់រំកុមារតូច។ (ប្រសិនបើប្រើប្រាស់វីដេអូ សូមប្រើតែវីដេអូ ឯកសារនៃកុមារអាយុពី០ទៅ៣ឆ្នាំប៉ុណ្ណោះ)។<br><br>បន្ទាប់មកអ្នកសម្របសម្រួលត្រូវសួរសិក្ខាកាមថា : តើអ្នកបានសិក្សាអ្វីខ្លះពីផ្ទាំងរូបភាព (ឬពីខ្សែវីដេអូ) ទាំងនេះ?។ អ្នកសម្របសម្រួលត្រូវទុកពេលឱ្យសិក្ខាកាមម្នាក់ ឬពីរនាក់បញ្ចេញយោបល់របស់ខ្លួន។ | -ផ្ទាំងរូបភាព ឬវីដេអូឯកសារ |
| ៥នាទី | ៤. សង្ខេបអត្ថន័យនៃផ្ទាំងរូបភាព<br>អ្នកសម្របសម្រួលត្រូវសង្ខេបអត្ថន័យនៃផ្ទាំងរូបភាព (ឬខ្សែវីដេអូ) អំពីអ្វីដែលលោកអ្នកអាចអនុវត្តសម្រាប់កុមារអាយុក្រោម៣ឆ្នាំ ដើម្បីជួយដល់ការអភិវឌ្ឍរបស់ពួកគេ :<br>• ការអភិវឌ្ឍចាប់ផ្តើមតាំងពីពេលចាប់កំណើត<br>• កុមារត្រូវការនូវការយកចិត្តទុកដាក់ និងការលើកទឹកចិត្ត<br>• កុមារត្រូវការនូវការប្រាស្រ័យទាក់ទង<br>ជាបន្តអ្នកសម្របសម្រួលត្រូវសង្កត់ធ្ងន់ថា "វាជាការសំខាន់ណាស់ដែលឪពុកម្តាយត្រូវយកចិត្តទុកដាក់ និងលើកទឹកចិត្ត ហើយឪពុកម្តាយត្រូវនិយាយ និងលេងជាមួយកូនតាមដែលអាចធ្វើទៅបាន។ មធ្យោបាយសំខាន់ដែលជួយកុមារឱ្យមានការអភិវឌ្ឍ គឺការបញ្ជូនកូនទៅថ្នាក់មត្តេយ្យ នៅពេលគេមានអាយុពី៣ទៅ៥ឆ្នាំ"។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | ៥. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលត្រូវបិទក្រដាសផ្ទាំងធំ ដែលមានសរសេររួចជាស្រេច អំពី ២.២. គំនិតសំខាន់ៗមួយចំនួន ដែលអាចជួយជំរុញដល់ការអភិវឌ្ឍរបស់កុមារតូច ឬស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ២.២ នេះ។ អ្នកសម្របសម្រួលអញ្ជើញសិក្ខាកាមអានមួយចំណុចម្តងៗ ហើយបន្ទាប់មកពន្យល់បកស្រាយ។<br>គំនិតសំខាន់ៗ ដែលអាចជួយជំរុញដល់ការអភិវឌ្ឍរបស់កុមារតូច :<br>• ការពារកុមារពីគ្រោះថ្នាក់ដល់រាងកាយ<br>• មានអាហារូបត្ថម្ភ និងការថែទាំសុខភាពគ្រប់គ្រាន់<br>• ទទួលបានថ្នាំបង្ការគ្រប់គ្រាន់<br>• មានភាពជិតស្និទ្ធជាមួយមនុស្សចាស់<br>• មានមនុស្សចាស់ដែលអាចយល់ និងឆ្លើយតបទៅកុមារវិញ<br>• មានវត្ថុឱ្យគេមើល ប៉ះ ស្តាប់ឮ ស្រង់ក្លិន និងភ្លក្សរសជាតិ<br>• មានឱកាសរកទីក និងស្រាវជ្រាវរកពាក្យដែលគេចង់ប្រើ<br>• យកចិត្តទុកដាក់ចំពោះការប្រើប្រាស់ភាសា<br>• យកចិត្តទុកដាក់ និងគាំទ្រក្នុងការទទួលនូវសមត្ថភាពថ្មី ការអភិវឌ្ឍជំនាញភាសា និងការគិត<br>• រៀនពីរបៀបគ្រប់គ្រងលើឥរិយាបថរបស់ពួកគេ<br>• ផ្តល់ឱកាសឱ្យកុមារបានលេង | ខ្លឹមសារមេរៀន២.២ |
| ១០នាទី | ៦. ការបំផុសសំណួរ និងបង្ហាញខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលត្រូវចោទជាសំណួរទៅសិក្ខាកាមថា តើហេតុអ្វីបានជាយើងគិតថា ការបញ្ជូនកូនទៅថ្នាក់មត្តេយ្យ ជាមធ្យោបាយមួយសំខាន់ ដើម្បីជួយកុមារឱ្យមានការអភិវឌ្ឍ?។ អ្នកសម្របសម្រួលត្រូវកត់ត្រានូវចម្លើយរបស់សិក្ខាកាមដាក់លើក្តារខៀន ឬលើផ្ទាំងក្រដាសធំ។<br>ចម្លើយអាចមាន :<br>• ជំរុញការអភិវឌ្ឍ លូតលាស់ខាងរូបរាងកាយ ផ្នែកប្រាជ្ញាស្មារតី និងផ្នែកអារម្មណ៍របស់កុមារ។<br>• លើកទឹកចិត្តកុមារឱ្យមានការត្រៀមទុកជាមុន សម្រាប់ការចូលរៀនសាលា | ខ្លឹមសារមេរៀន២.៣ |

| រយៈពេល | សកម្មភាព | ធនធាន |
| --- | --- | --- |
| | បឋមសិក្សា ។<br>• កុមារបានចូលថ្នាក់មត្តេយ្យ មានសកម្មភាពសិក្សានៅសាលាបឋមសិក្សាបានល្អជាងកុមារ ដែលមិនបានឆ្លងថ្នាក់មត្តេយ្យ ។<br>• ជួយដល់ការកែលម្អការចុះឈ្មោះចូលរៀនថ្នាក់ទី១ នៅពេលគ្រប់អាយុ៦ឆ្នាំ ។<br>• ចូលរួមកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សានៅសាលាបឋមសិក្សា ។<br>• ផ្តល់ឱកាសឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិអប់រំ និងការអភិវឌ្ឍ ។<br>• . . . ។ល ។<br><br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ២.៣.ការអប់រំកុមារតូច ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ។ | |
| ៥នាទី | ៧. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ២.៤.សេវាកម្មអប់រំមួយចំនួនសម្រាប់ការអប់រំកុមារតូច (អាយុពី៣.៥ឆ្នាំ) ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ។ | ខ្លឹមសារមេរៀន២.៤ |
| ៣៥នាទី | ៨. ការពិភាក្សាតាមក្រុម<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជា២ក្រុមធំៗ ។ ក្រុមទី១ពិភាក្សាលើករណីទី១ និងក្រុមទី២ពិភាក្សាលើករណីទី២ ។ នៅក្នុងក្រុមនីមួយៗ ត្រូវពិភាក្សារកឱ្យឃើញនូវមូលហេតុនៃបញ្ហាផ្តល់នូវដំណោះស្រាយនៃបញ្ហាដែលបានរកឃើញនោះ ។<br><br>ដើម្បីជួយសម្រួលក្នុងការបែងចែកក្រុមពិភាក្សា អ្នកសម្របសម្រួលគួរឱ្យសិក្ខាកាមលេងល្បែងមួយមានឈ្មោះថា "ខ្យល់បក់" ។ សុំឱ្យសិក្ខាកាមឈរជារង្វង់មួយ ហើយអ្នកសម្របសម្រួលត្រូវពន្យល់ថា : នៅពេលខ្ញុំនិយាយថា "ខ្យល់បក់អ្នកពាក់ស្បែកជើងពណ៌ខ្មៅ" ពេលនោះអ្នករាល់គ្នាដែលមានពាក់ស្បែកជើងពណ៌ខ្មៅត្រូវតែផ្លាស់ប្តូរកន្លែងចេញពីរង្វង់ទៅកន្លែងមួយផ្សេងទៀត តែអ្នកដែលមិនពាក់ស្បែកជើងពណ៌ខ្មៅមិនចាំបាច់ផ្លាស់ប្តូរកន្លែងឡើយ ។ អ្នកសម្របសម្រួលអាចលែងល្បែងនេះ៤ដង ដោយនិយាយថា "ខ្យល់បក់អ្នកដែលមានសក់រួញ" "ខ្យល់បក់អ្នកដែលពាក់អាវយឺត" | -ឯកសារលំហាត់២.១ (ករណីទី១ និងករណីទី២)<br>-ក្រដាសផ្ទាំងធំ ហ្វឺត និងស្កុត |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | "ខ្យល់បក់អ្នកដែលស្លៀកពាក់ខោអាវពណ៌ក្រហម"។<br><br>សម្គាល់ : ល្បែងនេះអាចជួយអ្នកសម្របសម្រួល ក្នុងការចែកក្រុមពិភាក្សាដោយធ្វើឱ្យមានការផ្លាស់ប្តូរ សមាសភាពក្រុមបានមួយចំនួន និងមានសមាសភាពចំរុះ។<br><br>បន្ទាប់ពីធ្វើការបែងចែកក្រុមរួចហើយ អ្នកសម្របសម្រួលត្រូវចែកជូនក្រុមនីមួយ១ នូវខ្លឹមសារសម្រាប់ការពិភាក្សា (ករណីទី១ និងករណីទី២) និងពន្យល់អំពីរបៀបពិភាក្សា។ តំណាងក្រុមនីមួយ១ ត្រូវឡើងបង្ហាញលទ្ធផលរបស់ក្រុមខ្លួន។ | |
| ៥នាទី | ១០. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ២.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់២.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់២.២ |

## ឯកសារលំហាត់ ២.១

**ករណីទី១ :**

ពុំមានថ្នាក់មត្តេយ្យនៅក្នុងភូមិ ឃុំ សង្កាត់របស់យើង។ តើអ្វីខ្លះជាមូលហេតុដែលបណ្តាលឱ្យភូមិ ឃុំ សង្កាត់របស់យើងពុំមានថ្នាក់មត្តេយ្យសម្រាប់កុមារ? តើអ្វីដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើបាន ដើម្បីឱ្យមានសេវាកម្មសម្រាប់កុមារ?

**ករណីទី២ :**

មានថ្នាក់មត្តេយ្យសហគមន៍នៅក្នុងឃុំ សង្កាត់របស់យើង ប៉ុន្តែមានកុមារមករៀនតិច តើអ្វីខ្លះជាមូលហេតុ? តើអ្វីដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើបាន ដើម្បីជំរុញឱ្យកុមារមករៀនបានច្រើនជាងមុន?

## ចម្លើយអាចមានចំពោះករណីទី១ :

| មូលហេតុ | ដំណោះស្រាយ |
|---|---|
| ការិយាល័យអប់រំ យុវជន និងកីឡាស្រុក មិនមានលទ្ធភាពផ្តល់មូលនិធិ សម្រាប់បង្កើតថ្នាក់មត្តេយ្យក្នុងភូមិនេះ។ | • ឃុំ សង្កាត់ត្រូវដាក់អាទិភាពមត្តេយ្យសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់<br>• ប្រើប្រាស់ថវិកាឃុំ សង្កាត់ដើម្បីដំណើរការថ្នាក់មត្តេយ្យសហគមន៍<br>• ប្រសិនបើមានមូលនិធិដែលផ្តល់ដោយអ្នកផ្តល់ជំនួយ ឬសប្បុរសជន ឃុំ សង្កាត់អាចពិចារណា ក្នុងការប្រើប្រាស់មូលនិធិនោះ សម្រាប់បង្កើតថ្នាក់មត្តេយ្យ<br>• ប្រមូលការចូលរួមពីមាតាបិតាដើម្បីផ្តល់ការគាំទ្រ |
| ពុំមានព័ត៌មានគ្រប់គ្រាន់អំពីកុមារអាយុ៣-៥ឆ្នាំ | • ប្រមូលទិន្នន័យកុមារដែលមានអាយុពី៣-៥ឆ្នាំ |
| គ្មានដីសម្រាប់សាងសង់ថ្នាក់មត្តេយ្យ | • ពិភាក្សាជាមួយមេភូមិ មេឃុំ ចៅសង្កាត់ ដើម្បីស្វែងរកដីសាធារណៈដែលអាចសាងសង់ថ្នាក់មត្តេយ្យបាន |
| ពុំមានគ្រូមត្តេយ្យ | • ជ្រើសរើសអ្នកដែលមានលទ្ធភាពឱ្យធ្វើជាគ្រូមត្តេយ្យ<br>• សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់គ្រូ ។ |

## ចម្លើយអាចមានចំពោះករណីទី២ :

| មូលហេតុ | ដំណោះស្រាយ |
|---|---|
| សហគមន៍មិនទាន់ចាត់ទុកថាការអភិវឌ្ឍកុមារតូចមានសារៈសំខាន់។ | ចូលរួមជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ក្នុងការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ។ |
| ឪពុក ម្តាយពុំទាន់យល់ពីសារៈសំខាន់នៃការបញ្ជូនកូនទៅថ្នាក់មត្តេយ្យ។ | បង្កើនការយល់ដឹងដែលបញ្ជាក់ថាវាជាការចាំបាច់ណាស់ដែលកុមារត្រូវតែចូលរៀននៅថ្នាក់មត្តេយ្យ។ |
| ក្រុមគ្រួសារមានជីវភាពក្រីក្រ | ជាគោលការណ៍ រៀននៅថ្នាក់មត្តេយ្យមិនតម្រូវឱ្យបង់ប្រាក់ទេ ប៉ុន្តែបើមានបញ្ហានេះ គួរតែមានមូលនិធិសម្រាប់ជួយឱ្យកុមារបានទៅរៀន។ |
| មាតាបិតាគិតថា កូននៅក្មេងនៅឡើយ មិនទាន់ចាំបាច់ទៅសាលារៀន | បង្កើនការយល់ដឹងជាសាធារណៈថា ការអភិវឌ្ឍរបស់កុមារ គឺចាប់ផ្តើមតាំងពីកំណើត ហើយទទួលការយល់ដឹងពីការយកចិត្តទុកដាក់និងទំនាក់ទំនងតាំងពីដំបូង។ |
| មត្តេយ្យសហគមន៍ និងថ្នាក់ថែទាំកុមារតូចតាមផ្ទះ មិនឃើញមានបង្រៀនអ្វីសោះ | បង្កើនការយល់ដឹងថាកុមារអាចសិក្សាបានប្រសើរ តាមការច្រៀង និងលេង |

## ឯកសារលំហាត់ ២.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ប្រមូលទិន្នន័យកុមារដែលមានអាយុពី៣-៥ឆ្នាំ
- ដាក់អាទិភាពមត្តេយ្យសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ប្រើប្រាស់ថវិកាឃុំ សង្កាត់ដើម្បីដំណើរការថ្នាក់មត្តេយ្យសហគមន៍
- ប្រមូលការចូលរួមពីមាតាបិតាដើម្បីផ្តល់ការគាំទ្រ
- ស្វែងរកដីសាធារណៈដើម្បីសាងសង់ថ្នាក់មត្តេយ្យ
- ជ្រើសរើសអ្នកដែលមានលទ្ធភាពឱ្យធ្វើជាគ្រូមត្តេយ្យ
- សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុងដើម្បីផ្តល់ការបណ្តុះបណ្តាលដល់គ្រូ
- ចូលរួមជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ក្នុងការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈថា ការអភិវឌ្ឍរបស់កុមារ គឺចាប់ផ្តើមតាំងពីកំណើត ។

# ប្លង់មេរៀនទី៣
# ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីសារប្រយោជន៍នៃការបញ្ជូនកូនទៅរៀនបានទៀងទាត់។<br>• កំណត់បាននូវសេវាអប់រំចម្បង១មួយចំនួនដែលអាចមានសម្រាប់ប្រជាពលរដ្ឋខ្មែរ។<br>• មានលទ្ធភាពរៀបចំសកម្មភាពដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តដើម្បីជួយដោះស្រាយបញ្ហា និងលើកបញ្ហាទាំងនេះ ជាអាទិភាពនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។ |
| រយៈពេលសរុប | ប្រហែល ៨០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងឯកសារលំហាត់៣.១. ៣.២.។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការពិភាក្សាលើករណីសិក្សា ការពិភាក្សាជាក្រុម និងការបង្ហាញ។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | ១. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលផ្ដើមដោយសួរទៅសិក្ខាកាមថា តើអ្វីជាការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ?។ ត្រូវតក់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្ដារខៀន ឬក្រដាសផ្ទាំងធំ។ អ្នកសម្របសម្រួលបូកសរុបចម្លើយរបស់សិក្ខាកាម ដោយបង្ហាញខ្លឹមសារដូចខាងក្រោម (ខ្លឹមសារមេរៀន ៣.១) :<br>ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ សំដៅដល់ការអប់រំប្រាំបួនថ្នាក់ដំបូង គឺចាប់ពីថ្នាក់ទីមួយ ដល់ថ្នាក់ទីប្រាំបួននៃការអប់រំចំណេះទូទៅក្នុងប្រព័ន្ធ ឬការអប់រំកម្រិតសមមូល។ ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ មានគោលបំណង ដើម្បីបំពេញសេចក្ដីត្រូវការចំណេះដឹងជាមូលដ្ឋាន សម្រាប់ប្រជាពលរដ្ឋ និងជាមូលដ្ឋានសម្រាប់ការសិក្សាបន្តទៀត។ | ខ្លឹមសារ មេរៀន៣.១ |
| ១៥នាទី | ២. ការបំផុសសំណួរ និងការបង្ហាញខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលត្រូវបន្តសំណួរថា តើកុមារមានសិទ្ធិអ្វីខ្លះពាក់ព័ន្ធនឹងការអប់រំមូលដ្ឋានក្នុងប្រព័ន្ធនេះ?។ ត្រូវតក់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្ដារខៀន ឬក្រដាសផ្ទាំងធំ។<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៣.២.សេវាកម្មអប់រំ | ខ្លឹមសារមេរៀន ៣.២ និង ៣.៣ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | សម្រាប់កម្រិតបឋមសិក្សា (កុមារអាយុពី៦-១១ឆ្នាំ) និង ៣.៣.សេវាកម្មអប់រំសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ (កុមារអាយុពី១២-១៤ឆ្នាំ)។ អ្នកសម្របសម្រួលត្រូវទុកពេលវេលាឱ្យបានគ្រប់គ្រាន់ដល់សិក្ខាកាម ដើម្បីអានព័ត៌មានក្នុងតារាងទាំង២នេះ។ ករណីចាំបាច់អ្នកសម្របសម្រួល ត្រូវអានព័ត៌មាននោះខ្លាំងៗ និងពន្យល់ដល់សិក្ខាកាម។<br><br>អ្នកសម្របសម្រួលបញ្ចប់សកម្មភាពនេះ ដោយបញ្ជាក់ដល់សិក្ខាកាមថា "ព័ត៌មានទាំងនេះបង្ហាញពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរទាំងអស់ ក្នុងការទទួលបានសេវាកម្មអប់រំ។ ប្រសិនបើសេវាកម្មទាំងនោះមិនទាន់បានផ្ដល់ដល់ប្រជាពលរដ្ឋ ក្នុងនាមជាក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានកាតព្វកិច្ចជួយប្រជាពលរដ្ឋឱ្យទទួលបានសេវាកម្មទាំងនោះ"។ | |
| ២៥នាទី | ៣. ការពិភាក្សាទៅលើករណីសិក្សា<br>អ្នកសម្របសម្រួលចែកឯកសារករណីសិក្សាដល់សិក្ខាកាម ហើយឱ្យសិក្ខាកាមអានម្នាក់មួយវាក្យខណ្ឌៗ រហូតដល់ចប់ ។ បន្ទាប់មកអ្នកសម្របសម្រួល សួរសំណួរខាងក្រោមនេះ :<br>• តើលោកអ្នកគិតថា វាមានបញ្ហាអ្វីកើតឡើងនៅក្នុងករណីសិក្សានេះ?<br>• តើបញ្ហាទាំងនេះ វាបណ្ដាលមកពីមូលហេតុអ្វីខ្លះ?<br>• បើមានបញ្ហាបែបនេះ នឹងផ្ដល់ផលប៉ះពាល់អ្វីខ្លះ?<br>អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្ដារខៀន ឬក្រដាសផ្ទាំងធំ ។<br><table><tr><th>បញ្ហា</th><th>មូលហេតុ</th><th>ផលប៉ះពាល់</th></tr><tr><td></td><td></td><td></td></tr></table> | ឯកសារលំហាត់៣.១. ករណីសិក្សា |
| ២៥នាទី | ៤. ការពិភាក្សាតាមក្រុម<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមមានសមាជិក៥ ឬ៦នាក់ និងណែនាំអំពីរបៀបពិភាក្សា : ក្រុមនីមួយៗ ត្រូវពិភាក្សាគ្នាដើម្បីរកដំណោះស្រាយសមស្របនានា ចំពោះបញ្ហាដែលរកឃើញនៅក្នុងការពិភាក្សាទៅលើករណីសិក្សា។ តំណាងក្រុមនីមួយៗ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | បង្ហាញ លទ្ធផលពិភាក្សារបស់ក្រុម ។<br>**ដំណោះស្រាយអាចមាន :**<br>• ប្រមូលព័ត៌មានពីចំនួនកុមារដែលបោះបង់ចោលការសិក្សា<br>• ប្រមូលកុមារដែលបោះបង់ចោលការសិក្សាឱ្យត្រឡប់មកសាលារៀនវិញ<br>• ផ្សព្វផ្សាយពីសារៈសំខាន់នៃការទៅរៀនទៀងទាត់<br>• ការធ្វើវិមជ្ឈការកាលវិភាគអាស្រ័យតាមតម្រូវការរបស់សិស្ស ( ពេលវេលាសិក្សាអាចផ្លាស់ប្ដូរទៅតាមតម្រូវការជាក់ស្ដែងនៅមូលដ្ឋាន)<br>• រាយការណ៍ជូននាយកសាលា ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ដើម្បីជួយដោះស្រាយបញ្ហា<br>• វិនិយោគលើមធ្យោបាយធ្វើដំណើរក្នុងភូមិ (រ៉ឺម៉កសាលារៀនមួយក្នុងមួយភូមិ) ដើម្បីដឹកជញ្ជូនកុមារនៅតំបន់ឆ្ងាយដាច់ស្រយាលទៅ និងត្រឡប់ពីសាលារៀន<br>• ជំនួយអាហារូបករណ៍ដល់កុមារក្រីក្រ<br>• . . . ។ល ។ | |
| ១០នាទី | ៥. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៣.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម ។ អ្នកសម្របសម្រួលផ្ដល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់៣.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ ។ | ឯកសារលំហាត់៣.២ |

## ឯកសារលំហាត់ ៣.១ : ករណីសិក្សា

សាលាបឋមសិក្សាត្រឡៀងកែងស្ថិតនៅក្នុងឃុំខ្ពស់ ជាសាលាដែលមានអត្រាសិស្សបោះបង់ចោលការសិក្សារហូតដល់ទៅ៧% ដែលនេះជាអត្រាខ្ពស់ជាងគេបំផុតនៅក្នុងខេត្ត។ ភូមិជាច្រើនក្នុងឃុំនេះ ស្ថិតនៅក្នុងតំបន់ដាច់ស្រយាលឆ្ងាយពីទីប្រជុំជន និងមានចម្ងាយយ៉ាងតិច២.៥គីឡូម៉ែត្រពីសាលារៀន។ នាព្រឹកមួយ ពេលដែលពូចែវកំពុងជិះកង់ទៅធ្វើការ គាត់បានឃើញក្មេង១មួយក្រុម ក្នុងនោះមានក្មេងស្រី២នាក់ ក្មេងប្រុស៣នាក់ កំពុងជិះលើខ្នងក្របីច្រៀងលេងយ៉ាងសប្បាយ។ គាត់ឈប់កង់ ហើយសួរទៅក្មេង១ទាំងនោះថា "នែ! ក្មួយ១ តើថ្ងៃនេះជាថ្ងៃអ្វី?" ក្មេង១ទាំងនោះឆ្លើយយ៉ាងរហ័សថា "ថ្ងៃអង្គារ លោកពូ" ពូចែវ សួរទៀតថា "ចុះពួកក្មួយអត់ទៅរៀនទេឬ?"។ ក្មេងប្រុសម្នាក់ឆ្លើយឡើងថា "បាទយើងត្រូវទៅរៀន តែពុក និងម៉ែពួកខ្ញុំឱ្យឈប់រៀន៣ថ្ងៃ ដើម្បីជួយឃ្វាលក្របី ព្រោះពួកគាត់រវល់ច្រូតស្រូវបង្ហើយ"។ ពូចែវបន្តទៀតថា "អីចឹងទេ! តើពួកក្មួយគិតឃើញយ៉ាងណាដែរនៅពេលត្រឡប់ទៅរៀនវិញបន្ទាប់ពីឈប់៣ថ្ងៃនេះ?"។

ឮដូច្នេះក្មេង១ទាំងនោះចាប់ផ្តើមរៀបរាប់ប្រាប់ពូចែវ ពីបញ្ហាដែលពួកគេជួបប្រទះនៅពេលដែលគេមិនបានទៅរៀនឱ្យបានជាប់លាប់។ វុធ និងមិត្តរបស់គេឈ្មោះថាប ត្រូវរៀនត្រួតថ្នាក់នៅថ្នាក់ទី៣ ឯមិត្តរបស់គេម្នាក់ទៀតឈ្មោះរិទ្ធ តាមមិនទាន់មេរៀននៅក្នុងថ្នាក់ ហើយក៏មិនចង់ទៅសាលារៀនទៀតដែរ។

ពូចែវបែរទៅរកក្មេងស្រីទាំងពីរ និងសួរថា "ចំណែកក្មួយស្រីតូច? តើក្មួយគិតយ៉ាងណា?" ក្មេងស្រីដែលមានអាយុប្រហែល១៣ឆ្នាំ ឈ្មោះនាងឆ្លើយថា "ខ្ញុំមិនមែនក្មេងតូចទៀតទេលោកពូ! ខ្ញុំស្រឡាញ់សាលារៀនណាស់ ហើយខ្ញុំខំរៀនអាននៅផ្ទះ ដូច្នេះខ្ញុំមិនជួបការលំបាកក្នុងការយល់មេរៀនទេ ប៉ុន្តែពុក និងម៉ែរបស់ខ្ញុំ គាត់ចង់ឱ្យខ្ញុំរៀបការនៅឆ្នាំក្រោយ ដូច្នេះខ្ញុំមិនអាចបញ្ចប់ថ្នាក់ទី៦បានឡើយ"។ ក្មេងស្រីម្នាក់ទៀតឈ្មោះសុភាពបានប្រាប់ថា ឪពុករបស់ខ្លួនមានជំងឺធ្ងន់ធ្ងរ ហើយនាងប្រហែលជាឈប់រៀនដូចក្មេងស្រីឈ្មោះនាងដែរ ដើម្បីស្វែងរកការងារធ្វើរកប្រាក់ជួយគ្រួសារ។

សំណួរសម្រាប់ពិភាក្សា :

- តើលោកអ្នកគិតថា វាមានបញ្ហាអ្វីកើតឡើងនៅក្នុងករណីសិក្សានេះ?
- តើបញ្ហាទាំងនេះ វាបណ្តាលមកពីមូលហេតុអ្វីខ្លះ?
- បើមានបញ្ហាបែបនេះ នឹងផ្តល់ផលប៉ះពាល់អ្វីខ្លះ?

## ចម្លើយអាចមាន :

| បញ្ហា | មូលហេតុ | ផលប៉ះពាល់ |
|---|---|---|
| • អត្រាសិស្សបោះបង់ចោលការសិក្សាខ្ពស់ | • សាលារៀននៅឆ្ងាយពីភូមិ<br>• កុមារត្រូវជួយធ្វើកិច្ចការឪពុកម្ដាយ<br>• កុមារត្រូវជួយថែទាំជំងឺឪពុកម្ដាយ<br>• ឪពុក ម្ដាយមានបំណងឱ្យកូនរៀបការ<br>• ជីវភាពក្រីក្រ<br>• ឪពុកម្ដាយ មិនទាន់យល់ពីសារៈសំខាន់នៃការសិក្សា | • ក្លាយជាអនក្ខរជន<br>• ពិបាករកការងារធ្វើនៅពេលពេញវ័យ<br>• មិនអាចចេញផុតពីភាពក្រីក្រជារៀងរហូត<br>• ងាយធ្លាក់ចូលក្នុងការឆបោករបស់អ្នកដទៃ<br>• រៀនត្រួតថ្នាក់ |

## ឯកសារលំហាត់ ៣.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ប្រមូលព័ត៌មានពីចំនួនកុមារដែលបោះបង់ចោលសាលារៀន
- ប្រមូលកុមារដែលបោះបង់ចោលសាសាឱ្យត្រឡប់មកសាលារៀនវិញ
- ផ្សព្វផ្សាយពីសារៈសំខាន់នៃការទៅរៀនទៀងទាត់
- រាយការណ៍ជូននាយកសាលា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ដើម្បីជួយដោះស្រាយបញ្ហា
- វិនិយោគលើមធ្យោបាយធ្វើដំណើរក្នុងភូមិ
- រៀបចំឱ្យមានអាហារូបករណ៍ដល់កុមារក្រីក្រ

# ប្លង់មេរៀនទី៤
# ការអប់រំអក្ខរកម្ម

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• មានលទ្ធភាពកំណត់មនុស្សក្នុងឃុំ សង្កាត់ដែលនឹងទទួលផលប្រយោជន៍ពីថ្នាក់អក្ខរកម្ម<br>• ដឹងអំពីរបៀបចាប់ផ្តើមកម្មវិធីថ្នាក់អក្ខរកម្មនៅក្នុងឃុំ សង្កាត់<br>• មានលទ្ធភាពកំណត់សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តដើម្បីកែលម្អស្ថានភាពអក្ខរកម្មនៅក្នុងឃុំ សង្កាត់ ឱ្យកាន់តែល្អប្រសើរឡើង។ |
| រយៈពេលសរុប | ប្រហែល ៩០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ ស្រោមសំបុត្រទំហំ១ភាគ៣នៃអា៤ចំនួន១០ និងឯកសារលំហាត់ ៤.១, ៤.២, ៤.៣, ៤.៤, ៤.៥។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការពិភាក្សាជាក្រុម ការសម្តែងតួ និងការបង្ហាញ។ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការពិភាក្សាតាមក្រុម**<br>អ្នកសម្របសម្រួលចាប់ផ្តើមមេរៀននេះ ដោយចែកសិក្ខាកាមពិភាក្សាជាក្រុមដែលមានសមាជិកពី៥-៦នាក់ និងចែកស្រោមសំបុត្រមួយសម្រាប់មួយក្រុម (ដែលនៅក្នុងស្រោមសំបុត្រនេះមានប័ណ្ណមួយជាភាសាបរទេស ដែលឃ្លានីមួយៗត្រូវបានកាត់ជា៣បំណែក) ដល់គ្រប់ក្រុមទាំងអស់ ហើយពន្យល់ថា : មានសេចក្តីថ្លែងការណ៍ចំនួន៣ស្តីពីស្ថានភាពអប់រំ នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានកាត់ចេញជាបំណែកៗ។ ការងាររបស់ក្រុមនីមួយៗ ដែលត្រូវធ្វើនៅពេលនេះ គឺត្រូវភ្ជាប់បំណែកប័ណ្ណទាំងនោះទៅតាមលំដាប់លំដោយ ដើម្បីឱ្យសេចក្តីថ្លែងការណ៍ទាំងនោះ មានន័យត្រឹមត្រូវ។ អ្នកសម្របសម្រួលទុកពេល៣នាទី ឱ្យក្រុមនីមួយៗធ្វើកិច្ចការនេះ។ បន្ទាប់មកទៀត អ្នកសម្របសម្រួលត្រូវពិនិត្យមើល ហើយប្រមូលប័ណ្ណមកវិញ (សិក្ខាកាមទំនងជាមិនអាចធ្វើកិច្ចការនេះបានទេ)។<br>**– 8 out of 10 Cambodian males are literate.**<br>**– 6 out of 10 Cambodian females are literate.**<br>**- 1.5 million Cambodian are illiterate.** | ឯកសារលំហាត់៤.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ជាបន្តអ្នកសម្របសម្រួលត្រូវចែកស្រោមសំបុត្រមួយថ្មីជូនទៅក្រុមនីមួយៗ ដែលក្នុងស្រោមសំបុត្រថ្មីនេះមានសេចក្តីថ្លែងការណ៍ដែលសរសេរជាភាសាខ្មែរ ហើយឃ្លានីមួយៗត្រូវកាត់ចេញជាពាបំណែកៗ។ អ្នកសម្របសម្រួលត្រូវស្នើឱ្យក្រុមនីមួយៗបំពេញការងារដូចលើកមុន។ ផ្តល់ពេលឱ្យក្រុមនីមួយៗ ដើម្បីផ្គុំសេចក្តីថ្លែងការណ៍ទាំងនេះឱ្យត្រឹមត្រូវ។<br>**ចម្លើយដែលត្រឹមត្រូវ :**<br>• បុរសកម្ពុជា៨នាក់ក្នុងចំណោម១០នាក់ចេះអាន និងសរសេរ។<br>• ស្ត្រីកម្ពុជា៦នាក់ ក្នុងចំណោម១០នាក់ចេះអាន និងសរសេរ។<br>• ប្រជាពលរដ្ឋកម្ពុជាចំនួន១.៥លាននាក់ជាអនក្ខរជន។ | |
| ៤នាទី | **២. ការបំផុសសំណួរ**<br>បន្ទាប់ពីបានចម្លើយ អ្នកសម្របសម្រួលសុំឱ្យអ្នកស្ម័គ្រចិត្តម្នាក់អានឱ្យឮខ្លាំងៗ និងទុកពេលឱ្យសិក្ខាកាមពិចារណាលើសេចក្តីថ្លែងការណ៍ទាំងនោះ។ បន្ទាប់មកអ្នកសម្របសម្រួលត្រូវសួរទៅសិក្ខាកាមថា តើលោកអ្នកយល់ឃើញដូចម្តេចចំពោះស្ថិតិ នៅក្នុងសេចក្តីថ្លែងការណ៍នេះ?<br>**ចម្លើយអាចមាន :**<br>• ចំនួនបុរសចេះអាន និងចេះសរសេរច្រើនជាងចំនួនស្ត្រីចេះអាន និងចេះសរសេរ<br>• ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា នៅមានចំនួនច្រើនដែលមិនទាន់ចេះអាន និងចេះសរសេរ | |
| ៣នាទី | **៣. ការបំផុសសំណួរ**<br>អ្នកសម្របសម្រួលបន្តសួរទៅសិក្ខាកាមថា "តើលោកអ្នកមានអារម្មណ៍យ៉ាងណាប្រសិនបើលោកអ្នក មិនចេះអានអំពីអ្វីដែលបានសរសេរនៅលើប័ណ្ណដែលបានចែកជូនលើកទី១?។ អ្នកសម្របសម្រួលត្រូវកត់ត្រាចម្លើយនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br>**ចម្លើយអាចមាន :**<br>• មានអារម្មណ៍ថាខ្លួនឯងមិនសូវមានប្រយោជន៍<br>• មានអារម្មណ៍ថាដូចជាមនុស្សងងឹតភ្នែក<br>• មានអារម្មណ៍ថាត្រូវការជំនួយ<br>• . . . ។ល។ | |

| រយៈពេល | សកម្មភាព | ធនធាន |
| --- | --- | --- |
| ៧នាទី | ៤. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលត្រូវបន្តសួរសិក្ខាកាមថា :<br>• តើអ្វីទៅជាការចេះអាន និងចេះសរសេរ?<br>• តើលោកអ្នកមានអារម្មណ៍យ៉ាងណាចំពោះការចេះអាន និងសរសេរ?<br>• តើលោកអ្នកអាចធ្វើអ្វីបានខ្លះពីការចេះអាន និងសរសេរ?<br>• តើវាមានសារប្រយោជន៍អ្វីខ្លះសម្រាប់មនុស្សម្នាក់ៗ?<br>កត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។<br><br>ចម្លើយអាចមាន :<br>• អាចអានផ្លាកមុខទំនិញនៅលើដប ឬកំប៉ុង<br>• អាចអានក្រដាសខិតប័ណ្ណដែលគេចែកឱ្យ<br>• អាចអានសារព័ត៌មាន ( កាសែត)<br>• អាចមានការងារផ្សេងក្រៅពីធ្វើស្រែចំការ<br>• អាចយល់ពីសារៈសំខាន់នៃគម្រោង ឬកម្មវិធីអភិវឌ្ឍន៍មួយចំនួន<br>• អាចរិះរកពីវិធីជួយខ្លួនឯងបានល្អប្រសើរ<br>• អាចចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសហគមន៍ និងសង្គម<br>• អាចឈរឈ្មោះឱ្យគេបោះឆ្នោតធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេភូមិ<br>• អាចសរសេរសំបុត្រទៅសួរសុខទុក្ខបងប្អូន<br>• មានអារម្មណ៍ល្អចំពោះខ្លួនឯង<br>• គិតថាខ្លួនឯងជាមនុស្សមានប្រយោជន៍<br>• អាចគិតលុយ និងរាប់ចំនួនបានត្រឹមត្រូវ<br>• . . . ។ល។ | |
| ២៨នាទី | ៥. ការពិភាក្សាតាមក្រុមទៅលើករណីសិក្សា<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមដែលមានសមាជិកពី៥-៦នាក់ ចែកឯកសារលំហាត់៤.២.ករណីសិក្សារឿងរបស់ធីតា និងណែនាំអំពីរបៀបពិភាក្សា : ក្រុមនីមួយត្រូវអានសាច់រឿងឱ្យយល់ច្បាស់ បន្ទាប់មកពិភាក្សាគ្នាដោយប្រើតារាងខាងក្រោម ។ | ឯកសារលំហាត់៤.២ |

<table>
<tr><th>រយៈពេល</th><th>សកម្មភាព</th><th>ធនធាន</th></tr>
<tr><td></td><td>នៅក្នុងពេលពិភាក្សាតាមក្រុម អ្នកសម្របសម្រួលដើរពិនិត្យមើលការពិភាក្សាតាមក្រុមនីមួយៗ និងកត់សម្គាល់នូវក្រុមណាមួយដែលបានពិភាក្សារកឃើញនូវបញ្ហា មូលហេតុ និងដំណោះស្រាយសមស្របជាងគេ ហើយត្រូវអញ្ជើញតំណាងក្រុមនោះឱ្យឡើងបង្ហាញលទ្ធផល។ ក្រុមដទៃទៀតត្រូវពិនិត្យមើលលទ្ធផលរបស់ខ្លួន ឬមានគំនិតផ្សេងទៀត ដើម្បីបន្ថែមលើលទ្ធផលរបស់ក្រុមដែលកំពុងបង្ហាញ។
<table>
<tr><th>បញ្ហាដែលកើតមានក្នុងករណីសិក្សា</th><th>មូលហេតុ</th><th>ផលប៉ះពាល់</th><th>ដំណោះស្រាយ</th></tr>
<tr><td></td><td></td><td></td><td></td></tr>
</table></td><td></td></tr>
<tr><td>៣នាទី</td><td>៦. ការបញ្ជាក់<br>បន្ទាប់ពីការបង្ហាញចប់ អ្នកសម្របសម្រួលត្រូវបញ្ជាក់ដល់សិក្ខាកាមថា :<br>យើងទាំងអស់គ្នាត្រូវយល់ពីសារៈសំខាន់នៃការអប់រំសម្រាប់ទាំងអស់គ្នា : នោះវាមានន័យថា វាមិនមែនសម្រាប់តែកុមារអាយុ៦ឆ្នាំប៉ុណ្ណោះទេ គឺត្រូវតែគិតដល់កុមារដែលមានអាយុលើសពី៦ឆ្នាំ និងកុមារដែលបោះបង់ការសិក្សា ថាតើពួកគេទៅរៀនអាន និងសរសេរនៅឯណា? ត្រូវតែមានការខិតខំប្រឹងប្រែង ដើម្បីឱ្យកុមារបានចូលរៀននៅសាលាបឋមសិក្សាឡើងវិញ និងជំរុញយុវជននៅក្រៅសាលា ឱ្យទទួលបានកម្មវិធីអក្ខរកម្មពេញលេញ។</td><td></td></tr>
<tr><td>៧នាទី</td><td>៧. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់មេរៀនទី ៤.ការអប់រំអក្ខរកម្ម ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ។</td><td>ខ្លឹមសារមេរៀនទី៤</td></tr>
<tr><td>២៥នាទី</td><td>៨. ការសម្តែងតួ<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា ឥឡូវនេះយើងនឹងពិនិត្យមើលពីស្ថានភាពមួយទៀតដែលមានភាពខុសគ្នាទៅនឹងស្ថានភាពមុន។ ស្ថានភាពនោះ គឺយើងបានបើកថ្នាក់អក្ខរកម្មមួយកន្លែង តែយើងនៅតែមានបញ្ហា។</td><td>ឯកសារលំហាត់៤.៣ និង ៤.៤</td></tr>
</table>

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|

អ្នកសម្របសម្រួលចែកឯកសារលំហាត់៤.៣.ករណីសិក្សា (វគ្គទី២) ឱ្យទៅសិក្ខាកាម និងសុំឱ្យសិក្ខាកាមអាន មុននឹងសម្តែងរឿង។ បន្ទាប់មកអ្នកសម្របសម្រួលជម្រាបសិក្ខាកាមថា យើងនឹងរៀបចំការសម្តែងតួមួយ ដោយរៀបចំការប្រជុំមួយដែលដឹកនាំដោយមេឃុំ និងមានការចូលរួមពីតំណាងសិស្សអក្ខរកម្ម និងគ្រូអក្ខរកម្ម។

ការរៀបចំតួសម្តែងមានដូចខាងក្រោម :

- ១នាក់ : ដើរតួជាមេឃុំ
- ១នាក់ : ដើរតួជាអ្នកកត់ត្រា
- សិក្ខាកាមដែលនៅសល់ចែកជា២ក្រុម :
  - ក្រុម "ក" : តំណាងធីតា និងក្រុមនារីជំទង់ (ដើរតួជាសិស្សអក្ខរកម្ម)
  - ក្រុម "ខ" : តំណាងគ្រូអក្ខរកម្ម (ដើរតួរជាគ្រូអក្ខរកម្ម)

បន្ទាប់ពីរៀបចំតួសម្តែងរួច ទុកពេលប្រហែល៥នាទី ដើម្បីឱ្យក្រុមនីមួយៗ ពិភាក្សាគ្នាមុនចាប់ផ្តើមសម្តែងតួ។

ការរៀបចំឆាកសម្តែង :




ដំណើរការនៃការសម្តែងតួ :

- មេឃុំ : ចាប់ផ្តើមបើកកិច្ចប្រជុំដោយនិយាយថា យើងបានដឹងថាចាប់ពីពេលបើកថ្នាក់អក្ខរកម្មនៅក្នុងភូមិយើង រយៈពេលពីរសប្តាហ៍កន្លងមកនេះ ហាក់ដូចជាមិនទាន់ឃើញមានដំណើរការនៅឡើយ។ ហេតុនេះហើយ បានជាយើងរៀបចំឱ្យមានការប្រជុំក្នុងថ្ងៃនេះ ដើម្បីពិនិត្យមើលបញ្ហាពិតប្រាកដ និងរកមធ្យោបាយដោះស្រាយបញ្ហាទាំងនេះ។

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | • មេឃុំ : តើមានមូលហេតុអ្វីខ្លះបានជាថ្នាក់អក្ខរកម្មយើងមិនអាចដំណើរការទៅបាន?<br>• គ្រូអក្ខរកម្ម : ខ្ញុំបានទៅថ្នាក់អក្ខរកម្មជារៀងរាល់ថ្ងៃ ប៉ុន្តែមិនមានសិស្សមករៀនទេ តើឱ្យខ្ញុំបង្រៀនអ្នកណា?<br>• មេឃុំ : ហេតុអ្វីបានជាសិស្សមិនទៅរៀននៅថ្នាក់អក្ខរកម្ម? (សួរទៅក្រុមសិស្ស)<br>• សិស្ស : យើងទៅថ្នាក់អក្ខរកម្មរាល់ថ្ងៃ តែមិនបានឃើញអ្នកគ្រូទេ<br>• មេឃុំ : តើអ្នកគ្រូទៅថ្នាក់អក្ខរកម្មនៅម៉ោងប៉ុន្មាន? ហើយប្អូនៗទៅម៉ោងប៉ុន្មានបានជាមិនជួបអ្នកគ្រូ?<br>• អ្នកគ្រូ : ម៉ោង ៥:៣០ នាទីល្ងាច<br>• សិស្ស : ម៉ោង ៧យប់<br>• មេឃុំ : ហេតុអ្វីបានជាទៅថ្នាក់រៀនខុសពេលវេលាគ្នាអីចឹង?<br>• សិស្ស : ពួកយើងមិនអាចទៅរៀននៅម៉ោង ៥:៣០នាទីបានទេ ព្រោះជាពេលដែលពួកយើងទើបតែមកពីច្រូតស្រូវ ឬមកពីធ្វើចម្ការ។ យើងត្រូវរៀបចំបាយទឹកពេលល្ងាចរួច ទើបយើងអាចទៅថ្នាក់រៀនបាន។<br>• អ្នកគ្រូ : ថ្នាក់រៀនចាប់ផ្តើមនៅម៉ោង ៧យប់ដូច្នេះ វាត្រូវចប់នៅម៉ោង៨:៣០នាទីយប់ ដែលពេលនោះវាយប់ងងឹតខ្លាំង។ រូបខ្ញុំមានការលំបាកក្នុងការធ្វើដំណើរត្រឡប់ទៅផ្ទះវិញ។ ដូច្នេះខ្ញុំមិនអាចបង្រៀនបានទេ ។<br>• មេឃុំ : បើអញ្ចឹងតើមានដំណោះស្រាយអ្វីទេ? (សួរទៅទាំងអស់គ្នា)<br>• សិស្ស : យើងនឹងជ្រើសរើសរកក្រុមអ្នកស្ម័គ្រចិត្ត ដើម្បីជូនអ្នកគ្រូទៅផ្ទះនៅពេលបញ្ចប់ថ្នាក់រៀន<br>• អ្នកគ្រូ : បើអញ្ចឹងខ្ញុំសុខចិត្តមកបង្រៀននៅពេលយប់<br>• មេឃុំ : អញ្ចឹងយើងរកដំណោះស្រាយបានហើយ។ ពីថ្ងៃនេះទៅទាំងអស់គ្នាត្រូវមកថ្នាក់រៀននៅម៉ោង៧យប់ ហើយពេលចប់ថ្នាក់រៀននៅម៉ោង៨:៣០នាទីយប់ ត្រូវជូនអ្នកគ្រូទៅផ្ទះ ដើម្បីធានាសុវត្ថិភាពជូនគាត់។ សូមបិទអង្គប្រជុំ។ | |
| ៣នាទី | ៩. ការបញ្ជាក់<br>បន្ទាប់ពីបញ្ចប់ការសម្តែងតួ អ្នកសម្របសម្រួលពន្យល់ថា ដើម្បីឱ្យសេវាកម្មនានាត្រូវបានផ្តល់យ៉ាងល្អ ភាគីពាក់ព័ន្ធត្រូវតែមានទំនាក់ទំនង ត្រូវសហការ និង | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | បំពេញការងារឱ្យបានល្អ ដើម្បីឆ្ពោះទៅរកដំណោះស្រាយរួមមួយ។ វាមានសារប្រយោជន៍ណាស់ដែលឃុំ សង្កាត់ សហគមន៍ និងស្ថាប័នអប់រំផ្តល់ការគាំទ្រថ្នាក់អក្ខរកម្ម និងកម្មវិធីចូលរៀនឡើងវិញ ដើម្បីផ្តល់ឱកាសដល់កុមារដែលមិនធ្លាប់បានចូលសាលា និងកុមារដែលបោះបង់ការសិក្សាទទួលបាននូវអក្ខរកម្មពេញលេញ។ | |
| ៥នាទី | ១០. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៤.៥.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់៤.៥ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៤.៥ |

## ឯកសារលំហាត់ ៤.១

- **8 out of 10 Cambodian males are literate.**
- **6 out of 10 Cambodian females are literate.**
- **1.5 million Cambodian are illiterate.**

---

- បុរសកម្ពុជា៨នាក់ក្នុងចំណោម១០នាក់ចេះអាន និងសរសេរ។
- ស្ត្រីកម្ពុជា៦នាក់ ក្នុងចំណោម១០នាក់ចេះអាន និងសរសេរ។
- ប្រជាពលរដ្ឋកម្ពុជាចំនួន១,៥លាននាក់ជាអនក្ខរជន ។

## ឯកសារលំហាត់ ៤.២ : ករណីសិក្សារឿងធីតា

ថ្ងៃមួយពូ វីន បានធ្វើដំណើរជាមួយសមាជិកក្រុមគ្រួសាររបស់គាត់ ទៅកាន់រមណីយដ្ឋានធម្មជាតិបឹងយក្សឡោម នៅក្នុងខេត្តរតនគិរី។ បន្ទាប់ពីពួកគេដើរលេង និងងូតទឹករួចមក គាត់ក៏បាននាំកូនស្រីរបស់គាត់ដែលមានអាយុ៧ឆ្នាំ ទៅទិញនំអន្សមអាំងរបស់ក្មេងស្រីជំទង់ម្នាក់ឈ្មោះធីតា ដែលកំពុងតែអង្គុយអាំងនំអន្សមនៅក្រោមម្លប់ឈើ។ កូនស្រីពូវីន បានសួរទៅធីតាថា តើអន្សមអាំងរបស់បងស្រីលក់មួយថ្លៃប៉ុន្មាន? ធីតាឆ្លើយថា ចាស លក់មួយថ្លៃ ៥០០រៀល។ កូនស្រីពូវីន បានតបទៅវិញថា បើអញ្ចឹងសូមបងស្រីខ្ចប់នំអន្សមអាំងឱ្យខ្ញុំចំនួន៧នំមក ហើយគិតលុយទៅ តើវាអស់ថ្លៃប៉ុន្មាន? ។ ធីតាក៏រើសយកនំអន្សម ដែលអាំងឆ្អិន និងរាប់ម្តងមួយៗដាក់ក្នុងស្បោង ហើយហុចឱ្យទៅកូនស្រីពូវីន ដោយមិនបន្លឺសម្លេងអ្វីបន្តិចសោះ។ ពេលនោះកូនពូវីន ក៏សួរទៅធីតាម្តងទៀត តើនំអន្សមអាំងទាំង៧នេះអស់ថ្លៃប៉ុន្មាន? ធីតានៅតែមិនអាចឆ្លើយបាន។ ឃើញដូច្នោះ ពូវីនក៏ប្រាប់ថាអស់ថ្លៃ៣.៥០០រៀល។ ប្រាប់រួចហើយពូវីន ក៏ហុចលុយក្រដាស៥.០០០រៀលឱ្យទៅធីតា ដើម្បីទូទាត់ថ្លៃនំអន្សម។ ឃើញពូវីនហុចក្រដាសប្រាក់ ៥.០០០រៀលដូច្នោះ ធីតាកាន់តែមានទឹកមុខស្លេកស្លាំងព្រោះនាងមិនដឹងថា នាងត្រូវអាប់លុយឱ្យទៅវិញប៉ុន្មានរៀល។ ឃើញសភាពបែបនេះ កូនស្រីពូវីនបានប្រាប់ទៅនាងធីតាថា បងស្រីត្រូវអាប់លុយចំនួន១.៥០០រៀល ជូនឪពុកខ្ញុំវិញ។ នាងធីតាក៏អាប់លុយ១.៥០០រៀលឱ្យទៅពូវីន។ នាងធីតាមានការស្រពោនចិត្តយ៉ាងខ្លាំង ដោយនាងបានឃើញក្មេងស្រីតូច ក្មេងជាងនាង តែបែរជាចេះគិតលុយយ៉ាងលឿនជាងនាងទៅទៀត។ នាងធីតាបានគិតក្នុងចិត្តថា ហេតុតែនាងមានផ្ទះនៅឆ្ងាយ និងរស់នៅក្នុងជីវភាពក្រីក្រ នាងបានចូលរៀនត្រឹមថ្នាក់ទី២ប៉ុណ្ណោះ នាងត្រូវបញ្ឈប់ការសិក្សា ដោយសារតែនាងត្រូវជួយធ្វើការឪពុកម្តាយដើម្បីទ្រទ្រង់ជីវភាព ទើបគ្មានឱកាសបានបន្តការរៀនសូត្រដូចគេ។ ឥឡូវនេះ នាងធំជ្រុលទៅហើយ និងមិនដឹងថាត្រូវទៅរៀននៅឯណាទេ។

| បញ្ហាដែលកើតមាន ក្នុងករណីសិក្សា | មូលហេតុ | ផលប៉ះពាល់ | ដំណោះស្រាយ |
|---|---|---|---|
| | | | |

**ចម្លើយដែលអាចមាន :**

| បញ្ហាដែលកើតមានក្នុងករណីសិក្សា | មូលហេតុ | ផលប៉ះពាល់ | ដំណោះស្រាយ |
|---|---|---|---|
| ធីតាមិនអាចគិតលុយ | • ធីតារៀនបានតិច<br>• ផ្ទះនៅឆ្ងាយពីសាលា<br>• ជីវភាពគ្រួសារក្រីក្រ | • មិនអាចលក់ដូរ<br>• បាត់បង់ប្រាក់ចំណូល | • ត្រូវបើកថ្នាក់អក្ខរកម្ម |

## ឯកសារលំហាត់ ៤.៣ : ករណីសិក្សារឿងថ្នាក់អក្ខរកម្ម

នៅក្នុងឃុំពង្រលើ មានក្មេងស្រីជំទង់ ដែលជាអនក្ខរជនដូច**ធីតា**ជាច្រើននាក់ ហេតុនេះទើបបានជានៅក្នុងដំណើរការកសាងផែនការឃុំនាឆ្នាំកន្លងទៅ ក្រុមប្រឹក្សាឃុំបានលើកបញ្ហានេះជាអាទិភាពខ្ពស់នៅក្នុងផែនការ និង កម្មវិធីវិនិយោគអភិវឌ្ឍន៍ឃុំ និងបានចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីចាប់ដំណើរការថ្នាក់អក្ខរកម្មចំនួន២ថ្នាក់មួយនៅក្នុងភូមិតាត្រី និងមួយទៀតនៅក្នុងភូមិឪឡឹក គឺជាភូមិដែលត្រូវបានកំណត់រកឃើញថា មានអត្រាអនក្ខរជនច្រើនជាងភូមិដទៃទៀតក្នុងឃុំ ។

**ធីតា** បានទៅថ្នាក់អក្ខរកម្មដែលស្ថិតក្នុងភូមិតាត្រី ។ ផ្អែកតាមសេចក្តីរាយការណ៍របស់ស្មៀនឃុំ បានឱ្យដឹងថា គ្រូបង្រៀនអក្ខរកម្ម គឺអ្នកគ្រូ**សុជាតិ** ធ្វើការនៅទីនោះ ប៉ុន្តែជារៀងរាល់ថ្ងៃគ្មានឃើញសិស្សណាម្នាក់ទៅរៀននៅថ្នាក់អក្ខរកម្មនោះឡើយ ទោះបីជាមានសិស្សដល់ទៅ៣៥នាក់ បានចុះឈ្មោះចូលរៀនក៏ដោយ ។ អ្នកគ្រូ**សុជាតិ** បានទទួលប្រាក់ឧបត្ថម្ភពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងធ្លាប់បានទទួលការបណ្តុះបណ្តាលយ៉ាងល្អ ស្តីពីជំនាញក្នុងការបង្រៀននៅថ្នាក់អក្ខរកម្ម ហើយនាងក៏មានសម្ភារបង្រៀនគ្រប់គ្រាន់សម្រាប់ការបណ្តុះបណ្តាលផងដែរ ។

# ឯកសារលំហាត់ ៤.៤ : ការសម្តែងតួ

១). ការរៀបចំតួសម្តែងមានដូចខាងក្រោម :

- ១នាក់ : ដើរតួជាមេឃុំ
- ១នាក់ : ដើរតួជាអ្នកកត់ត្រា
- សិក្ខាកាមដែលនៅសល់ចែកជា២ក្រុម :
  - ក្រុម "ក" : តំណាងធីតា និងក្រុមនារីជំទង់ (ដើរតួជាសិស្សអក្ខរកម្ម)
  - ក្រុម "ខ" : តំណាងគ្រូអក្ខរកម្ម (ដើរតួជាគ្រូអក្ខរកម្ម)

បន្ទាប់ពីរៀបចំតួសម្តែងរួច ទុកពេលប្រហែល៥នាទី ដើម្បីឱ្យក្រុមនីមួយៗពិភាក្សាគ្នា មុនចាប់ផ្តើមសម្តែងតួ។

២). ការរៀបចំឆាកសម្តែង :




៣). ដំណើរការនៃការសម្តែងតួ :

- មេឃុំ : ចាប់ផ្តើមបើកកិច្ចប្រជុំដោយនិយាយថា យើងបានដឹងថាចាប់ពីពេលបើកថ្នាក់អក្ខរកម្មនៅក្នុងភូមិយើងរយៈពេលពីរសប្តាហ៍កន្លងមកនេះ ហាក់ដូចជាមិនទាន់ឃើញមានដំណើរការនៅឡើយ ។ ហេតុនេះហើយបានជាយើងរៀបចំឱ្យមានការប្រជុំក្នុងថ្ងៃនេះ ដើម្បីពិនិត្យមើលបញ្ហាពិតប្រាកដ និងរកមធ្យោបាយដោះស្រាយបញ្ហាទាំងនេះ ។
- មេឃុំ : តើមានមូលហេតុអ្វីខ្លះបានជាថ្នាក់អក្ខរកម្មយើងមិនអាចដំណើរការទៅបាន?
- គ្រូអក្ខរកម្ម : ខ្ញុំបានទៅថ្នាក់អក្ខរកម្មជារៀងរាល់ថ្ងៃ ប៉ុន្តែមិនមានសិស្សមករៀនទេ តើឱ្យខ្ញុំបង្រៀនអ្នកណា?
- មេឃុំ : ហេតុអ្វីបានជាសិស្សមិនទៅរៀននៅថ្នាក់អក្ខរកម្ម? (សួរទៅក្រុមសិស្ស)
- សិស្ស : យើងទៅថ្នាក់អក្ខរកម្មរាល់ថ្ងៃ តែមិនបានឃើញអ្នកគ្រូទេ
- មេឃុំ : តើអ្នកគ្រូទៅថ្នាក់អក្ខរកម្មនៅម៉ោងប៉ុន្មាន? ហើយប្អូនៗទៅម៉ោងប៉ុន្មានបានជាមិនជួបអ្នកគ្រូ?
- អ្នកគ្រូ : ម៉ោង ៥:៣០ នាទីល្ងាច

- សិស្ស : ម៉ោង ៧យប់
- មេឃុំ : ហេតុអ្វីបានជាទៅថ្នាក់រៀនខុសពេលវេលាគ្នាអីចឹង?
- សិស្ស : ពួកយើងមិនអាចទៅរៀននៅម៉ោង៥:៣០នាទីបានទេ ព្រោះជាពេលដែលពួកយើងទើបតែមកពីច្រូតស្រូវឬមកពីធ្វើចំការ ។ យើងត្រូវរៀបចំបាយទឹកពេលល្ងាចរួច ទើបយើងអាចទៅថ្នាក់រៀនបាន ។
- អ្នកគ្រូ : ថ្នាក់រៀនចាប់ផ្តើមនៅម៉ោង៧យប់ ដូច្នេះវាត្រូវចប់នៅម៉ោង៨:៣០នាទីយប់ ដែលពេលនោះវាយប់ងងឹតខ្លាំង ។ រូបខ្ញុំមានការលំបាកក្នុងការធ្វើដំណើរត្រឡប់ទៅផ្ទះវិញ ។ ដូច្នេះខ្ញុំមិនអាចបង្រៀនបានទេ ។
- មេឃុំ : បើអញ្ចឹងតើមានដំណោះស្រាយអ្វីទេ? (សួរទៅទាំងអស់គ្នា)
- សិស្ស : យើងនឹងជ្រើសរើសរកក្រុមអ្នកស្ម័គ្រចិត្ត ដើម្បីជូនអ្នកគ្រូទៅផ្ទះនៅ ពេលបញ្ចប់ថ្នាក់រៀន
- អ្នកគ្រូ : បើអញ្ចឹងខ្ញុំសុខចិត្តមកបង្រៀននៅពេលយប់
- មេឃុំ : អញ្ចឹងយើងរកដំណោះស្រាយបានហើយ ។ ពីថ្ងៃនេះទៅទាំងអស់គ្នា ត្រូវមកថ្នាក់រៀននៅម៉ោង៧យប់ ហើយពេលចប់ថ្នាក់រៀននៅម៉ោង៨:៣០នាទីយប់ ត្រូវជូនអ្នកគ្រូទៅផ្ទះ ដើម្បីធានាសុវត្ថិភាពជូនគាត់ ។ សូមបិទអង្គប្រជុំ ។

### ឯកសារលំហាត់ ៤.៥ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ប្រមូលទិន្នន័យអនក្ខរជននៅក្នុងឃុំ សង្កាត់
- ដាក់អាទិភាពថ្នាក់អក្ខរកម្មទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ប្រើប្រាស់ថវិកាឃុំ សង្កាត់ដើម្បីដំណើរការថ្នាក់អក្ខរកម្ម
- ជ្រើសរើសអ្នកដែលមានលទ្ធភាពឱ្យធ្វើជាគ្រូថ្នាក់អក្ខរកម្ម
- រកទីកន្លែងសមរម្យដើម្បីបើកថ្នាក់អក្ខរកម្ម
- ប្រជុំជាមួយអ្នកភូមិដើម្បីកៀរគរការគាំទ្រថ្នាក់អក្ខរកម្ម
- សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុងដើម្បីផ្តល់ការបណ្តុះបណ្តាលដល់គ្រូអក្ខរកម្ម ។

# ប្លង់មេរៀនទី៥
# បំណិនជីវិត

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់ពីបំណិនជីវិតមូលដ្ឋានមួយចំនួនដែលបុគ្គលម្នាក់ៗត្រូវការ ដើម្បីដំណើរការជីវិតយ៉ាងមានប្រសិទ្ធភាពក្នុងសង្គម ។<br>• មានលទ្ធភាពកំណត់សកម្មភាពចាំបាច់ដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចជួយគាំទ្រដល់សកម្មភាពបំណិនជីវិត ។ |
| រយៈពេលសរុប | ប្រហែល ៤៥នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ និងឯកសារលំហាត់ ៥.១. ៥.២ ។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការពិភាក្សា និងការបង្ហាញ ។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | ១. ការបំផុសសំណួរ<br>អ្នកសម្របសម្រួលចាប់ផ្ដើមមេរៀននេះដោយនិយាយថា នៅមេរៀនមុននេះយើងបានដឹងរំពីការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ និងថ្នាក់រក្សរកម្ម ។ ពេលនេះយើងនឹងពិនិត្យមើលពីបំណិនជីវិត ។<br><br>បន្ទាប់មកអ្នកសម្របសម្រួលត្រូវបំផុសគំនិត ដោយសួរសិក្ខាកាមថា តើអ្វីជាបំណិនជីវិត? តើពាក្យថាបំណិនជីវិតមានន័យដូចម្ដេច? ។ ត្រូវកត់ត្រារាល់ចម្លើយរបស់សិក្ខាកាមដាក់លើក្ដារខៀន ឬក្រដាសផ្ទាំងធំ ។<br>ចម្លើយអាចមាន :<br>• ប៉ិនប្រសប់ក្នុងការថែទាំកូនចៅ<br>• ប៉ិនប្រសប់ក្នុងការបើកបរ<br>• ប៉ិនប្រសប់ក្នុងការរៀបចំផែនការក្នុងគ្រួសារ<br>• ប៉ិនប្រសប់ក្នុងការកាត់ដេរខោអាវ<br>• ប៉ិនប្រសប់ក្នុងការសាងសង់ផ្ទះ<br>• ប៉ិនប្រសប់ក្នុងការទំនាក់ទំនង និងនិយាយស្ដីជាមួយអ្នកភូមិ<br>• ប៉ិនប្រសប់ក្នុងការប្រមូលអ្នកភូមិឱ្យជួយគ្នាពេលមានបុណ្យទាន និងការរៀបចំពិធីផ្សេងៗ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | • ប៉ិនប្រសប់ក្នុងការដាំដំណាំ<br>• ប៉ិនប្រសប់ក្នុងការដាំដើមឈើ<br>• . . . ។ល។ | |
| ៥នាទី | ២. ការបំផុសសំណួរ និងការបង្ហាញខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលបន្តដោយលើកឡើងថា : អ្វីដែលលោកអ្នកបានលើកឡើង វាជាការពិតណាស់។ ជាទូទៅសម្រាប់មនុស្សយើងម្នាក់ៗ អាចបំពេញតួនាទីជាបុគ្គលម្នាក់ពេញលេញ ជាសមាជិកម្នាក់ក្នុងគ្រួសារ ជាសមាជិកម្នាក់ក្នុងសហគមន៍ ដែលយើងរស់នៅ យើងត្រូវតែមានជំនាញជាក់លាក់មួយចំនួន ដែលទាំងនោះត្រូវបានស្គាល់ថាជាបំណិនជីវិត។ បំណិនជីវិតធ្វើឱ្យយើងអាចរួមចំណែកដល់សហគមន៍ ដែលយើងរស់នៅផងដែរ។<br><br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៥.១.និយមន័យ ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ។ | ខ្លឹមសារ<br>មេរៀន៥.១ |
| ៥នាទី | ៣. ការពន្យល់<br>អ្នកសម្របសម្រួលបន្តការពន្យល់ដោយលើកឡើងថា បំណិនជីវិតមានច្រើនណាស់ តែបំណិនជីវិតទាំងអស់នេះ ត្រូវបានបែងចែកជាបួនប្រភេទសំខាន់ៗ :<br>• បំណិនជីវិតខាងសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួន<br>• បំណិនជីវិតក្នុងវិជ្ជាជីវៈបឋមដែលជួយឱ្យគេមានការងារធ្វើ<br>• បំណិនជីវិតក្នុងការរស់នៅក្នុងសង្គម សហគមន៍ (ប្រជាធិបតេយ្យ ច្បាប់ និងសិទ្ធិមនុស្ស)<br>• បំណិនជីវិតក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការថែរក្សាបរិស្ថាន | |
| ២០នាទី | ៤. ការពិភាក្សាតាមក្រុម<br>បន្ទាប់ពីការបង្ហាញចប់ អ្នកសម្របសម្រួលចែកសិក្ខាកាមជា៤ក្រុម ដើម្បីពិភាក្សា និងរកឧទាហរណ៍អំពីបំណិនជីវិតតាមប្រភេទនីមួយៗ។<br>• ក្រុមទី១ : បំណិនជីវិតខាងសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួន<br>• ក្រុមទី២ : បំណិនជីវិតក្នុងវិជ្ជាជីវៈបឋមដែលជួយឱ្យគេមានការងារធ្វើ<br>• ក្រុមទី៣ : បំណិនជីវិតក្នុងជីវិតរស់នៅក្នុងសង្គម សហគមន៍ | ឯកសារ<br>លំហាត់៥.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | (ប្រជាធិបតេយ្យ ច្បាប់ និងសិទ្ធិមនុស្ស)<br>• ក្រុមទី៤ : បំណិនជីវិតក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការថែរក្សាបរិស្ថាន<br>ក្រុមនីមួយៗមានរយៈពេល១៥នាទី សម្រាប់ការពិភាក្សា។ តំណាងក្រុមនីមួយៗឡើងបង្ហាញពីលទ្ធផលនៃការពិភាក្សា។ | |
| ៥នាទី | ៥. ការបូកសរុបលទ្ធផលក្រុមពិភាក្សា (ការបង្ហាញខ្លឹមសារមេរៀន)<br>អ្នកសម្របសម្រួលបូកសរុបលទ្ធផលនៃក្រុមពិភាក្សា ដោយស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៥.២.ប្រភេទសំខាន់ៗនៃបំណិនជីវិត ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ។ | ខ្លឹមសារមេរៀន៥.២ |
| ៥នាទី | ៦. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៥.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់៥.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៥.២ |

## ឯកសារលំហាត់ ៥.១ :

- ក្រុមទី១ : បំណិនជីវិតខាងសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួន
- ក្រុមទី២ : បំណិនជីវិតក្នុងវិជ្ជាជីវៈបឋមដែលជួយឱ្យគេមានការងារធ្វើ
- ក្រុមទី៣ : បំណិនជីវិតក្នុងជីវិតរស់ក្នុងសង្គម សហគមន៍ (ប្រជាធិបតេយ្យ ច្បាប់ និងសិទ្ធិមនុស្ស)
- ក្រុមទី៤ : បំណិនជីវិតក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការថែរក្សាបរិស្ថាន

ចូររកឧទាហរណ៍ដែលទាក់ទងនឹងបំណិនជីវិតនៃប្រភេទនីមួយៗ

## ឯកសារលំហាត់ ៥.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- រៀបចំចងក្រងសហគមន៍ដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈ (ត្បាញកន្ទេល ជួសជុលម៉ាស៊ីន ដាំបន្លែ ធ្វើបង្អែម ធ្វើនំបុ័ង ធ្វើរទេះគោ ...)
- កំណត់រកអ្នកដែលមានជំនាញវិជ្ជាជីវៈអ្វីមួយច្បាស់លាស់ដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈដល់សហគមន៍
- រៀបចំកម្មវិធីប្រឡងប្រណាំងជំនាញ និងកីឡាផ្សេងៗ

# ប្លង់មេរៀនទី៦
# សមភាពយេនឌ័រក្នុងការអប់រំ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីសារៈសំខាន់នៃការសិក្សារបស់នារី និងកុមារី<br>• មានលទ្ធភាពរៀបចំផែនការសកម្មភាពដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តដើម្បីជំរុញដល់ការទទួលបានសេវាអប់រំសម្រាប់នារី និងកុមារី ។ |
| រយៈពេលសរុប | ប្រហែល ៧០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ និងឯកសារលំហាត់ ៦.១. ៦.២ ។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការពិភាក្សាជាក្រុម និងការបង្ហាញ ។ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១៥នាទី | **១. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន**<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៦.១.សេចក្តីផ្តើម ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ។ | ខ្លឹមសារមេរៀន៦.១ |
| ១០នាទី | **២. ការបំផុសសំណួរ**<br>អ្នកសម្របសម្រួលបំផុសសំណួរថា :<br>• តើហេតុអ្វីបានជានៅតែមានគម្លាតរវាងកុមារី និងកុមារាក្នុងការទទួលបានសេវាអប់រំយ៉ាងដូចនេះ?<br>• តើហេតុអ្វីបានជាចំនួនកុមារីកាន់តែថយចុះ នៅកម្រិតថ្នាក់សិក្សាកាន់តែខ្ពស់?<br>ចម្លើយរបស់សិក្ខាកាមត្រូវកត់ត្រានៅលើក្រដាសផ្ទាំងធំ ឬលើក្តារខៀន ។<br>**ចម្លើយអាចមាន :**<br>• ទុកកុមារីឱ្យជួយមើលថែទាំប្អូន<br>• កុមារីនៅជួយធ្វើការងារផ្ទះ<br>• ជីវភាពគ្រួសារក្រីក្រ<br>• ផ្ទះនៅឆ្ងាយពីសាលារៀន<br>• ឪពុកម្តាយឱ្យកូនស្រីរៀបការទាំងវ័យនៅក្មេង | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | • កុមារីត្រូវស្វែងរកការងារធ្វើដើម្បីគាំទ្រជីវភាពគ្រួសារ<br>• លក្ខខណ្ឌ និងបរិស្ថានសាលារៀនមិនទាន់សមស្របទៅនឹងតម្រូវការរបស់កុមារី ឬសិស្សស្រី<br>• ឪពុកម្តាយមួយចំនួនមិនទាន់យល់ពីសារៈសំខាន់នៃការអប់រំរបស់កុមារី | |
| ៥នាទី | ៣. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៦.២.និយមន័យសមភាពយេនឌ័រ ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ។ | ខ្លឹមសារមេរៀន៦.២ |
| ៣០នាទី | ៤. ការពិភាក្សាតាមក្រុម<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមដែលមានសមាជិក៥-៦នាក់ ចែកឯកសារលំហាត់៦.១ ហើយពន្យល់អំពីរបៀបដែលក្រុមនីមួយៗត្រូវពិភាក្សាថា : ក្រុមនីមួយៗត្រូវធ្វើការពិចារណាទៅលើទស្សនៈទាំង២ដែលបានចែកជូនថា ត្រឹមត្រូវ ឬមិនត្រឹមត្រូវ ហើយផ្តល់អំណះអំណាង និងឧទាហរណ៍ ។<br>• ទស្សនៈទី១ : អប់រំកុមារីម្នាក់ គឺអប់រំគ្រួសារទាំងមូល<br>• ទស្សនៈទី២ : នៅពេលដែលចំនួនកុមារីក្លាយជាអក្ខរជន (អ្នកចេះអក្សរ) កើនឡើង អត្រាមរណភាពរបស់កុមារអាយុក្រោម១ឆ្នាំធ្លាក់ចុះយ៉ាងឆាប់រហ័ស ។<br>សំណួរសម្រាប់ពិភាក្សា :<br>• តើអ្នកយល់ស្របតាមទស្សនៈនេះដែរឬទេ?<br>• បើយល់ស្របតាមទស្សនៈនេះ ចូរផ្តល់អំណះអំណាង និងឧទាហរណ៍ ។<br>• បើមិនយល់ស្របតាមទស្សនៈនេះ ចូរផ្តល់អំណះអំណាង និងឧទាហរណ៍ ។<br>ចម្លើយអាចមាន (យល់ស្របតាមទស្សនៈ) :<br>• កុមារីដែលបានទទួលការអប់រំ នាងនឹងក្លាយជាអ្នកមានសមត្ថភាពក្នុងការអប់រំគ្រួសាររបស់នាង ។<br>• កុមារីដែលបានទទួលការអប់រំ នាងនឹងក្លាយជាអ្នកមានសមត្ថភាព និងមានលទ្ធភាពខ្ពស់ ទាំងនៅផ្ទះ និងនៅក្នុងក្របខ័ណ្ឌការងារ ហើយជាពិសេសក្នុងការបំពេញការងារ ដែលទទួលបានប្រាក់ចំណូល ច្រើនសម្រាប់ផ្គត់ផ្គង់គ្រួសារ ។<br>• កុមារីដែលទទួលបានការអប់រំល្អ នាងនឹងក្លាយជាអ្នកយល់ដឹងច្បាស់ពីសារៈសំខាន់ | ឯកសារលំហាត់៦.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | នៃការអប់រំ ហើយនឹងបញ្ជូនកូនៗរបស់គេ ឱ្យទៅសាលារៀន ដែលធ្វើឱ្យគ្រួសារគេមានអនាគតល្អ ។<br>• កុមារីដែលទទួលបានការអប់រំល្អ នាងនឹងក្លាយជាអ្នកមានការយល់ដឹងច្បាស់អំពីរបៀបនៃការថែទាំសុខភាព និងយកចិត្តទុកដាក់ថែទាំកូនៗរបស់នាងបានល្អប្រសើរ ។<br>• កុមារីដែលទទួលបានការអប់រំល្អ នាងនឹងក្លាយជាអ្នកមានសមត្ថភាពក្នុងការគ្រប់គ្រងធនធាន ក្នុងគ្រួសារបានល្អប្រសើរ ។<br>• កុមារីដែលមានការអប់រំល្អ នាងនឹងក្លាយជាអ្នកមានជំនាញច្បាស់លាស់ និងមានទំនុកចិត្តលើខ្លួនឯង ដើម្បីធ្វើខ្លួនជាម្តាយ អ្នកដឹកនាំ មន្ត្រី និងប្រជាពលរដ្ឋល្អនៅក្នុងសង្គម ។<br>• . . . ។ល ។<br><br>នៅក្នុងពេលពិភាក្សា អ្នកសម្របសម្រួលដើរពិនិត្យមើលការពិភាក្សាតាមក្រុមនីមួយៗ និងកត់សម្គាល់លើក្រុមដែលមានចម្លើយសមស្របជាងគេ ។ តំណាងក្រុមនោះឡើងធ្វើការបង្ហាញលទ្ធផល និងក្រុមដទៃទៀតធ្វើការផ្ទៀងផ្ទាត់ចម្លើយរបស់ខ្លួន និងបន្ថែមលើចម្លើយណាដែលមិនទាន់សមស្រប ។ | |
| ៥នាទី | ៥. ការបូកសរុបលទ្ធផលក្រុមពិភាក្សា (ការបង្ហាញខ្លឹមសារមេរៀន)<br>អ្នកសម្របសម្រួលបូកសរុបលទ្ធផលនៃក្រុមពិភាក្សា ដោយស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៦.៣.ទស្សនៈយល់ដឹងអំពីផលប៉ះពាល់លើការអប់រំកុមារី ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ។ | ខ្លឹមសារមេរៀន៦.៣ |
| ៥នាទី | ៦. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៦.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម ។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់៦.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ ។ | ឯកសារលំហាត់៦.២ |

## ឯកសារលំហាត់ ៦.១ : ការពិភាក្សាតាមក្រុមទៅលើទស្សនៈ

- ទស្សនៈទី១ : អប់រំកុមារីម្នាក់ គឺអប់រំគ្រួសារទាំងមូល
- ទស្សនៈទី២ : នៅពេលដែលចំនួនកុមារីក្លាយជាអក្ខរជន (អ្នកចេះអក្សរ) កើនឡើង អត្រាមរណភាពរបស់កុមារអាយុក្រោម១ឆ្នាំធ្លាក់ចុះយ៉ាងឆាប់រហ័ស ។

សំណួរសម្រាប់ពិភាក្សា :

- តើអ្នកយល់ស្របតាមទស្សនៈនេះដែរឬទេ?
- បើយល់ស្របតាមទស្សនៈនេះ ចូរផ្តល់អំណះអំណាង និងឧទាហរណ៍ ។
- បើមិនយល់ស្របតាមទស្សនៈនេះ ចូរផ្តល់អំណះអំណាង និងឧទាហរណ៍ ។

## ឯកសារលំហាត់ ៦.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ប្រមូលនិងគ្រប់គ្រងទិន្នន័យស្តីពីចំនួនកុមារទាំងពីរភេទ
- ផ្សព្វផ្សាយព័ត៌មានអំពីការចូលរៀនដោយមិនបង់ថ្លៃ និងកម្មវិធីជួយដល់កុមារ
- ជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យបញ្ជូនកូនឱ្យចូលរៀនថ្នាក់មត្តេយ្យ ដើម្បីត្រៀមខ្លួនជាស្រេច មុនពេលចូលរៀននៅបឋមសិក្សា
- ចាត់ចែងបង្កើតក្រុមការពារកុមារី
- បង្កើតជាបន្ទប់ស្នាក់នៅរួម ឬអន្តេវាសិកដ្ឋានសម្រាប់កុមារី
- កំណត់កុមារីនៅក្នុងភូមិនីមួយៗ ដែលត្រូវការឧបត្ថម្ភអាហារូបករណ៍
- ស្វែងរកការគាំទ្រដល់កុមារីទាំងនោះ នៅក្នុងការប្រជុំគណៈកម្មាធិការគ្រប់គ្រងកម្មវិធីអាហារូបករណ៍មូលដ្ឋាន ។
- ជំរុញការជ្រើសរើសបេក្ខភាពជានារីធ្វើជាគ្រូបង្រៀន

# ប្លង់មេរៀនទី៧
# គុណភាពនៃការអប់រំ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• យល់ច្បាស់អំពីសកម្មភាពដែលអាចកែលម្អគុណភាពនៃការអប់រំ<br>• ជួយលើកកម្ពស់គុណភាពនៃការអប់រំនៅក្នុងសហគមន៍ ដោយការចូលរួមយ៉ាងសកម្ម នៅក្នុងគណៈកម្មការពាក់ព័ន្ធនានា។ |
| រយៈពេលសរុប | ប្រហែល ៩០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ និងឯកសារលំហាត់ ៧.១. ៧.២។ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការពិភាក្សាជាក្រុម និងការបង្ហាញ។ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | **១. ការបំផុសសំណួរ**<br>អ្នកសម្របសម្រួលចាប់ផ្ដើមមេរៀនដោយសួរទៅសិក្ខាកាមថា តើសាលារៀនណាមួយនៅក្នុងឃុំ សង្កាត់ ស្រុក ខណ្ឌរបស់លោកអ្នក ដែលលោកអ្នកគិតថា វាល្អជាងគេ?។ អ្នកសម្របសម្រួល ត្រូវកត់ត្រាឈ្មោះសាលារៀនណាដែលសិក្ខាកាមភាគច្រើនផ្ដល់យោបល់ថាល្អជាងគេ នៅលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។<br><br>អ្នកសម្របសម្រួលបន្តសួរថា តើហេតុអ្វីបានជាលោកអ្នកគិតថាវាល្អជាងគេ? កត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្ដារខៀន ឬក្រដាសផ្ទាំងធំ។<br>**ចម្លើយអាចមាន :**<br>• នាយកសាលាហ្មត់ចត់ ឬមានប្រជាប្រិយភាព<br>• គ្រូមកបង្រៀនទៀងទាត់<br>• គ្រូបង្រៀនមានគុណភាពល្អ<br>• គ្រូបង្រៀនមានការប្ដេជ្ញាចិត្តខ្ពស់ និងប្រកបដោយមនសិការវិជ្ជាជីវៈ។<br>• សិស្សទទួលបានលទ្ធផលល្អ<br>• សាលារៀនមានរបង និងអគារល្អសមរម្យសក្ដិសមជាសាលាកុមារមេត្រី<br>• មានបង្គន់អនាម័យ និងអណ្ដូងទឹក | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | • មានសួនច្បារ និងដើមឈើលម្អក្នុងទីធ្លាសាលា<br>• មានបណ្ណាល័យដែលមានសៀវភៅអានគ្រប់គ្រាន់<br>• ឪពុកម្ដាយចូលរួមយ៉ាងសកម្មក្នុងការផ្ដល់ដំណឹងដល់សាលា<br>• មានទីធ្លាសម្រាប់ឱ្យសិស្សលេងកីឡា<br>• មានសុវត្ថិភាពល្អ | |
| ១០នាទី | ២. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៧.១.កត្តាសំខាន់ៗពាក់ព័ន្ធទៅនឹងគុណភាពអប់រំ ហើយអញ្ជើញសិក្ខាកាម្នាក់ ឬ២នាក់អានម្ដងមួយចំណុចៗ ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ ។ | ខ្លឹមសារមេរៀន៧.១ |
| ៤៥នាទី | ៤. ការពិភាក្សាតាមក្រុម<br>អ្នកសម្របសម្រួលបន្តដោយសំយោគថា ការបង្កើនគុណភាពអប់រំ ពិតជាទាមទារឱ្យមានការចូលរួមយ៉ាងជិតស្និទ្ធពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ នៅក្នុងនោះអ្នកពាក់ព័ន្ធសំខាន់៣ គឺ :<br>• ស្ថាប័នអប់រំ និងសាលារៀន<br>• អាជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ សង្កាត់)<br>• សហគមន៍ ឬអាណាព្យាបាលសិស្ស<br>បន្ទាប់មកអ្នកសម្របសម្រួលគូសតារាងខាងក្រោមនេះ រួចពន្យល់ដល់សិក្ខាកាម : | ឯកសារលំហាត់៧.១ |

| សមាសភាគ | តួនាទី | | |
|---|---|---|---|
| | ស្ថាប័នអប់រំ និងសាលារៀន | ក្រុមប្រឹក្សាឃុំ សង្កាត់ | សហគមន៍ អាណាព្យាបាល |
| សិស្ស | | | |
| គ្រូបង្រៀន | | | |
| ការគ្រប់គ្រងសាលា | | | |
| បរិស្ថានសាលា | | | |
| ការគាំទ្ររបស់អាជ្ញាធរមូលដ្ឋាន | | | |
| ការគាំទ្ររបស់សហគមន៍ និង | | | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | អ្នកសម្របសម្រួលចែកសិក្ខាកាមជា៣ក្រុម ចែកឯកសារលំហាត់៧.១ ហើយពន្យល់អំពីរបៀបដែលក្រុមនីមួយត្រូវពិភាក្សាថា ក្រុមនីមួយៗ ត្រូវធ្វើការពិភាក្សាអំពីតួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធមួយ ដើម្បីលើកកម្ពស់គុណភាពសេវាអប់រំ។ ក្រុមនីមួយៗ មានរយៈពេល២០នាទី ដើម្បីពិភាក្សាលើប្រធានបទនេះ បន្ទាប់មកតំណាងក្រុមនីមួយៗ ត្រូវឡើងបង្ហាញលទ្ធផលរបស់ក្រុម។<br>ប្រធានបទសម្រាប់ក្រុមពិភាក្សា :<br>ក្រុមទី១ : តួនាទី និងភារកិច្ចរបស់សាលារៀន (ស្ថាប័នអប់រំ និងសាលារៀន) ដើម្បីលើកកម្ពស់គុណភាពសេវាអប់រំ។<br>ក្រុមទី២ : តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីលើកកម្ពស់គុណភាពសេវាអប់រំ។<br>ក្រុមទី៣ : តួនាទី និងភារកិច្ចរបស់សហគមន៍ និងមាតាបិតាសិស្ស ដើម្បីលើកកម្ពស់គុណភាពសេវាអប់រំ។ | |
| ១០នាទី | ៤. ការបូកសរុបលទ្ធផលក្រុមពិភាក្សា (ការបង្ហាញខ្លឹមសារមេរៀន)<br>អ្នកសម្របសម្រួលបូកសរុបលទ្ធផលនៃក្រុមពិភាក្សា ដោយស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៧.២.អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការចូលរួមកែលម្អគុណភាពអប់រំ ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ។ | ខ្លឹមសារមេរៀន៧.២ |
| ៥នាទី | ៥. ការបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៧.៣.សេចក្តីសន្និដ្ឋាន ហើយអញ្ជើញសិក្ខាកាមម្នាក់ ឬ២នាក់អានម្តងមួយចំណុចៗ។ បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បកស្រាយ។ | ខ្លឹមសារមេរៀន៧.៣ |
| ១០នាទី | ៦. ការបង្ហាញ និងធ្វើសុពលភាព<br>អ្នកសម្របសម្រួលចែកឯកសារលំហាត់ ៧.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមទៅក្នុងឯកសារលំហាត់៧.២ នូវសកម្មភាពដែលបានបន្ថែមទាំងនោះ។ | ឯកសារលំហាត់៧.២ |

# ឯកសារលំហាត់ ៧.១ :
# ការពិភាក្សាតាមក្រុមទៅលើតួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

- ក្រុមទី១ : តួនាទី និងភារកិច្ចរបស់សាលារៀន (ស្ថាប័នអប់រំ និងសាលារៀន) ដើម្បីលើកកម្ពស់គុណភាពសេវាអប់រំ។
- ក្រុមទី២ : តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីលើកកម្ពស់គុណភាពសេវាអប់រំ។
- ក្រុមទី៣ : តួនាទី និងភារកិច្ចរបស់សហគមន៍ និងមាតាបិតាសិស្ស ដើម្បីលើកកម្ពស់គុណភាពសេវាអប់រំ។

| សមាសភាគ | តួនាទី | | |
|---|---|---|---|
| | ស្ថាប័នអប់រំ និងសាលារៀន | ក្រុមប្រឹក្សាឃុំ សង្កាត់ | សហគមន៍ អាណាព្យាបាល |
| សិស្ស | | | |
| គ្រូបង្រៀន | | | |
| ការគ្រប់គ្រងសាលា | | | |
| បរិស្ថានសាលា | | | |
| ការគាំទ្ររបស់អាជ្ញាធរមូលដ្ឋាន | | | |
| ការគាំទ្ររបស់សហគមន៍ និងមាតាបិតាសិស្ស | | | |

## ឯកសារលំហាត់ ៧.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ប្រមូលព័ត៌មាន ស្ថិតិកុមារដល់វ័យសិក្សាបោះបង់ការសិក្សា
- ការពារសុខសុវត្ថិភាពដល់កុមារនៅពេលទៅសាលារៀន និងពេលត្រឡប់មកផ្ទះវិញ
- ជួយពិនិត្យវត្តមានគ្រូបង្រៀននិងរាយការណ៍ទៅគណៈគ្រប់គ្រងសាលារៀន
- ផ្តល់កន្លែងស្នាក់នៅដល់គ្រូបង្រៀនមកពីតំបន់ឆ្ងាយ
- ការពារសុខសុវត្ថិភាពដល់គ្រូបង្រៀន
- ផ្តល់យោបល់លើការអភិវឌ្ឍសាលារៀន និងផលប៉ះពាល់គុណភាពអប់រំដល់គណៈគ្រប់គ្រងសាលា
- ផ្តល់ព័ត៌មាន ស្ថិតិរបស់កុមារអវត្តមាន ឬបោះបង់ការសិក្សាបានទាន់ពេលវេលា
- ធានាឱ្យមានបង្គន់អនាម័យ អណ្តូងទឹក សួនច្បារ នៅក្នុងទីធ្លាសាលារៀន . . .
- ជួសជុលអគារសិក្សាឧបករណ៍ប្រើប្រាស់របស់សាលារៀន
- ធានាសុខសុវត្ថិភាពបរិស្ថានសាលារៀន
- ចូលរួម គាំទ្រ ជំរុញសហគមន៍ក្នុងការអភិវឌ្ឍសាលារៀន
- ជំរុញមាតាបិតាសិស្សឱ្យបញ្ជូនកូនទៅរៀន
- កៀរគរធនធានដើម្បីអភិវឌ្ឍន៍សាលារៀន
- ផ្សព្វផ្សាយព័ត៌មានអប់រំផ្សេងៗ
- ដាក់បញ្ហាអប់រំទៅក្នុងរបៀបវារៈប្រជុំជាប្រចាំ
- រៀបចំឱ្យមានអ្នកមានសមត្ថភាពទទួលបន្ទុកការងារអប់រំ

# ប្លង់មេរៀនទី៨
# ការបូកសរុបផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង :<br>• ចេះពិនិត្យឡើងវិញអំពីសកម្មភាពនានាដែលបានពិភាក្សានៅក្នុងមេរៀនកន្លងមក<br>• ចេះចាត់អាទិភាពសកម្មភាពទាំងនោះ និងកំណត់អ្នកទទួលខុសត្រូវក្នុងការរៀបចំ និងអ្នកទទួលខុសត្រូវក្នុងការអនុវត្ត<br>• ចេះដាក់បញ្ចូលសកម្មភាពដែលបានព្រមព្រៀងទៅក្នុងផែនការសកម្មភាពប្រចាំខែរបស់ខ្លួនផ្ទាល់<br>• ព្រមព្រៀងដាក់បញ្ចូលបញ្ហាអប់រំទៅក្នុងរបៀបវារៈនៃការប្រជុំជាទៀតទាត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ |
| រយៈពេលសរុប | ប្រហែល ១២០នាទី |
| សម្ភារចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងឯកសារ ៨.១.សេចក្តីព្រាងផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន។ |
| វិធីសាស្ត្រ | ការបង្ហាញ និងការពិភាក្សាតាមក្រុមតូច។ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៣០នាទី | **១. ការបង្ហាញ និងពន្យល់ផែនការសកម្មភាព**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា "នៅក្នុងរយៈពេលជិតពីរថ្ងៃកន្លងទៅនេះ យើងទាំងអស់គ្នាបានពិភាក្សាអំពីបញ្ហាជាច្រើន និងបានលើកឡើងនូវផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីលើកកម្ពស់សេវាអប់រំ នៅក្នុងឃុំ សង្កាត់។ នៅពេលនេះ យើងធ្វើការបូកសរុបសកម្មភាពទាំងនោះឡើងវិញ"។<br><br>បន្ទាប់មកអ្នកសម្របសម្រួល ចែកឯកសារ ៨.១.សេចក្តីព្រាងផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើសុពលភាពនៃសកម្មភាពទាំងនោះជាមួយសិក្ខាកាម។ នៅក្នុងការពិភាក្សានេះ សិក្ខាកាមអាចស្នើបញ្ចូលសកម្មភាពបន្ថែម ឬកាត់ចោលសកម្មភាពមួយចំនួនដែលយល់ថាមិនអាចអនុវត្តបាន។<br><br>បន្ទាប់ពីព្រមព្រៀងទៅលើសកម្មភាពហើយ អ្នកសម្របសម្រួលត្រូវពន្យល់អំពីរបៀបបំពេញកូឡោនទី៣ កូឡោនទី៤ និងកូឡោនទី៥ នៃឯកសារ ៨.១ ដោយមានលើកឧទាហរណ៍យកមកបញ្ជាក់ជូនដល់សិក្ខាកាម។ | ឯកសារ ៨.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៩០នាទី | ២. ការពិភាក្សាតាមក្រុម<br>អ្នកសម្របសម្រួលចែកសិក្ខាកាមតាមឃុំ សង្កាត់នីមួយៗ (៨នាក់) ដើម្បីពិភាក្សាអំពីផែនការសកម្មរបស់ឃុំ សង្កាត់ខ្លួន។ ក្រុមនិមួយៗមានរយៈពេល៦០នាទី ដើម្បីអនុវត្តការពិភាក្សាគ្នា។ នៅក្នុងការពិភាក្សានេះ ក្រុមនីមួយៗក៏អាចបញ្ចូលសកម្មភាពនានាដែលខ្លួនយល់ថាសំខាន់ និងចាំបាច់។ នៅក្នុងអំឡុងពេលពិភាក្សាតាមក្រុមនេះ អ្នកសម្របសម្រួលត្រូវពិនិត្យមើលក្រុមនិមួយៗ ហើយជួយដល់ក្រុមណាដែលមិនទាន់យល់ច្បាស់។ តំណាងក្រុមនីមួយបង្ហាញលទ្ធផលក្រុមរបស់ខ្លួន ហើយបន្ទាប់មកអ្នកសម្របសម្រួល បូកសរុបដោយធ្វើការបំពេញបន្ថែម និងបំភ្លឺនូវរាល់ចំណុចទាំងឡាយដែលសិក្ខាកាមមិនទាន់យល់ច្បាស់។ | -ក្រដាសផ្ទាំងធំ ហ្វឺត និងស្កុត |

## ឧទ្រង់សម្រាប់ពន្យល់ ៨.១. ផែនការសកម្មភាពរបស់ឃុំ សង្កាត់..................ឈើបញ្ហាអប់រំ

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

សកម្មភាព: ស្រង់សកម្មភាពនានាដែលបានឯកភាពចូលក្នុងកូឡោននេះ ។

អ្នកចាត់ចែងសកម្មភាព: ឈ្មោះ តួនាទីអ្នកដែលទទួលខុសត្រូវក្នុងការរៀបចំ ឬចាត់ចែងសកម្មភាព ។

អ្នកអនុវត្តសកម្មភាព: ឈ្មោះ តួនាទីអ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពផ្ទាល់ ។

កំណត់សម្គាល់ផ្សេងៗ: ព័ត៌មានបន្ថែមដូចជា ពេលវេលា អ្នក ឬអង្គភាពរួមសហការ . . . ។ល។

## ៨.១. សេចក្តីព្រាងផែនការសកម្មភាពរបស់ឃុំ សង្កាត់......................លើបញ្ហាអប់រំ

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|
| ១ | ការគ្រប់គ្រងទិន្នន័យ : ប្រមូលនិងគ្រប់គ្រងទិន្នន័យស្តីពីចំនួនកុមារ និងអនក្ខរជនទាំងពីរភេទ : | | | |
| ១.១ | ទិន្នន័យកុមារដែលមានអាយុពី៣-៥ឆ្នាំ | | | |
| ១.២ | ទិន្នន័យកុមារដែលមានអាយុត្រូវចូលរៀន | | | |
| ១.៣ | ទិន្នន័យព័ត៌មានពីចំនួនកុមារដែលបោះបង់ចោលសាលារៀន | | | |
| ១.៤ | ប្រមូលទិន្នន័យអនក្ខរជននៅក្នុងឃុំ សង្កាត់ | | | |
| | | | | |
| ២ | ការផ្សព្វផ្សាយ | | | |
| ២.១ | ផ្សព្វផ្សាយពីសារសំខាន់ និងព័ត៌មាននៃការអប់រំ | | | |
| ២.២ | ចូលរួមជាមួយស្ថាប័នរបស់រៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ | | | |
| ២.៣ | បង្កើនការយល់ដឹងពីការចាំបាច់ដែលកុមារត្រូវតែចូលរៀននៅថ្នាក់មត្តេយ្យ | | | |
| ២.៤ | លើកទឹកចិត្តឪពុកម្តាយឱ្យបញ្ជូនកូនឱ្យចូលរៀនថ្នាក់មត្តេយ្យ | | | |
| ២.៥ | ជំរុញមាតាបិតាសិស្សឱ្យបញ្ជូនកូនទៅរៀននៅសាលា | | | |
| ២.៦ | ផ្សព្វផ្សាយព័ត៌មានអំពីការចូលរៀនដោយមិនបង់ថ្លៃ និងកម្មវិធីជួយដល់កុមារ | | | |
| ២.៧ | ផ្សព្វផ្សាយពីសារៈសំខាន់នៃការទៅរៀនទៀងទាត់ | | | |
| | | | | |
| | | | | |

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|
| ៣ | ការបញ្ចូលសកម្មភាពអប់រំក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ | | | |
| ៣.១ | ពិចារណាសកម្មភាពអប់រំជាសកម្មភាពអាទិភាពក្នុងផែនការឃុំ សង្កាត់ : | | | |
| ៣.២ | ការបង្កើតមត្តេយ្យសហគមន៍ | | | |
| ៣.៣ | ការបើកថ្នាក់អក្ខរកម្ម | | | |
| ៣.៤ | ផ្តល់ទីតាំងសាងសង់សាលារៀន | | | |
| ៣.៥ | បង្កើតជាបន្ទប់ស្នាក់នៅរួម ឬអន្តេវាសិកដ្ឋានសម្រាប់ កុមារី | | | |
| ៣.៦ | ការរៀបចំឱ្យមានអាហារូបករណ៍ដល់កុមារក្រីក្រ | | | |
| ៣.៧ | វិនិយោគលើមធ្យោបាយធ្វើដំណើរក្នុងភូមិដល់កុមារទៅសាលារៀន | | | |
| | | | | |
| ៤ | ការសហការជាមួយស្ថាប័នអប់រំដើម្បីកែលម្អគុណភាពអប់រំ | | | |
| ៤.១ | សហការជាមួយស្ថាប័នអប់រំដើម្បីជួយដោះស្រាយបញ្ហាគុណភាពអប់រំ | | | |
| ៤.២ | ធានាឱ្យមានបង្គន់អនាម័យ អណ្តូងទឹក សួនច្បារ នៅក្នុងទីធ្លាសាលារៀន | | | |
| ៤.៣ | ធានាសុវត្ថិភាព បរិស្ថានល្អ និងសន្តិសុខសាលារៀន | | | |
| ៤.៤ | ផ្តល់យោបល់លើការអភិវឌ្ឍសាលារៀន និងគុណភាពអប់រំ | | | |
| ៤.៥ | ជំរុញមាតាបិតាសិស្សដើម្បីផ្តល់ការគាំទ្រលើសកម្មភាពកែលម្អគុណភាពអប់រំ | | | |
| | | | | |

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|
| ៥ | **ការងារតាមដានសកម្មភាពអប់រំ** | | | |
| ៥.១ | បញ្ចូលបញ្ហាអប់រំទៅក្នុងរបៀបវារៈអង្គប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | | | |
| ៥.២ | ប្រមូលកុមារដែលបោះបង់ចោលសាលាឱ្យត្រឡប់មកសាលារៀនវិញ | | | |
| ៥.៣ | រាយការណ៍ទៅស្ថាប័នអប់រំដើម្បីជួយដោះស្រាយបញ្ហានៃការបោះបង់ចោលការសិក្សារបស់កុមារ | | | |
| ៥.៤ | រៀបចំឱ្យមានអ្នកមានសមត្ថភាពទទួលបន្ទុកការងារអប់រំ | | | |
| ៥.៥ | កំណត់កុមារីនៅក្នុងភូមិនីមួយៗ ដែលត្រូវការឧបត្ថម្ភអាហារូបករណ៍ | | | |
| ៥.៦ | ជំរុញការជ្រើសរើសបេក្ខភាពជានារីធ្វើជាគ្រូបង្រៀន | | | |
| ៥.៧ | ស្វែងរកការគាំទ្រដល់កុមារីទាំងនោះ នៅក្នុងការប្រជុំ ឬវេទិកាផ្សេងៗ | | | |
| ៥.៨ | ការពារសុខសុវត្ថិភាពដល់កុមារនៅពេលទៅសាលារៀន និងពេលត្រឡប់មកផ្ទះវិញ | | | |
| ៥.៩ | ផ្តល់កន្លែងស្នាក់នៅដល់គ្រូបង្រៀន មកពីតំបន់ឆ្ងាយ | | | |
| | | | | |
| | | | | |